# ការសំភាសន៍ជាលើកទី២របស់អ្នកមីង ធូ ចាន់ថុល

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ ធូ ចាន់ថុល

**<u>ការសង្ខេបរបស់អ្នកមីង ធូ ចាន់ថុល</u>**

នៅក្នុងការសំភាសន៍ជាលើកទី២នេះអ្នកមីង ធូ ចាន់ថុលបានប្រាប់ពីការសិក្សាថាគាត់រៀនបានត្រឹមតែថ្នាក់ទី៣ ។ហើយអ្នកមីងបានរៀបការនៅឆ្នាំ១៩៨៧ ហើយក្រោយមកបានកូន៣នាក់ស្វាមីអ្នកមីងបានទៅចោលគាត់ហើយ លែងត្រលប់ ហើយអ្នកមីងបានឈឺស្ទើរស្លាប់ព្រោះទឹមតែឆ្លងទន្លេរួច បន្ទាប់ពីកូនពៅបាន៩ឆ្នាំគាត់បានមានស្វាមីម្នាក់ទៀត។ អ្នកមីងបានឆ្លងកាត់របបលន់ នល់ ឃើញមានការទំលាក់គ្រាប់បែកហើយរបបប៉ុល ពត គឺមានការលំបាកហើយអត់ឃ្លាន ឪពុកត្រូវគេយកទៅសម្លាប់ចោល ។ អ្នកមីងមានការលំបាកក្នុងជីវភាពគ្រួសារព្រោះដោយសារភាពក្រីក្រហើយអ្នកផ្ទះឈឺហើយត្រូវខ្ចីលុយគេយកមកមើលជំងឺហើយជំពាក់លុយគេដើមជាការការជាដើម។

កៈ ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនាងខ្ញុំឈ្មោះឈ្មោះញ៉ែមសុគន្ធា ជាអ្នកសំភាសន៍អំពីជីវិតរបស់អ្នកមីងនៅក្នុងថ្ងៃនេះពួកយើងសំភាសន៍គឺនៅភូមិកោះគរ ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា។ ពួកយើងសំភាសន៍គឺនៅក្នុងខែមិនា ឆ្នាំ២០១៨ហើយអញ្ចឹងកាលពេលមុនញ៉ុមបានសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងម្តងរួចមក ហើយ អ៊ីចឹងញ៉ុមនឹងធ្វើការសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងជាលើកទី២ម្តងទៀត ដែលពីមុនអត់ទាន់បានដឹងទាំងអស់អំពីជីវិតអ្នកមីងក៏ដូចជាក្រុមគ្រួសារក៏ដូចជាជីវិតអ្នកមីងឆ្លងកាត់នៅក្នុងរបបសង្គ្រាមក៏ដូចជាដំនើរជីវិតនឹងការរកស៊ី ពីប្រពន្ធកូនចៅអំពីការសិក្សាអីអញ្ចឹងទៅអ្នកមីងណាស់!!មីងសូមប្រាប់ឈ្មោះម្តងទៀតមើល ឈ្មោះអីគេមីង?

ខៈ នាងខ្ញុំឈ្មោះធូ ចាន់ថុល។

កៈ សំរាប់អ្នកមីងអ្នកមីងរៀនបានសិក្សាដល់ថ្នាក់ទីប៉ុន្មានដែរអ្នកមីង?

ខៈ ញ៉ុមហោថ្នាក់ទី៣ហ្នឹង។

កៈ ទី៣ហេ !!ជំនាន់សង្គមឬក៏បែក?

ខៈ អត់ទេជំនាន់ហ្នឹង ជំនាន់ហ្នឹងញ៉ុមរៀនបានថ្នាក់ទី៣ គ្រាន់តែឡើងថ្នាក់ទី៣ញ៉ុមឈប់រៀនបណ្ដោយ!!

កៈ មូលហេតុអីដែរអ្នកមីង?

ខៈ មូលហេតុមកពីម្ដាយខ្ញុំអត់មានអ្នកណាគេជួយរកជួយធ្វើអីទាំងអស់អ៊ីចឹងមានតែញ៉ុមមួយដើរធ្វើស្រែធ្វើចំការចិញ្ចឹមបងប្អូនទាំងអស់ហ្នឹងអញ្ចឹងទៅ ហើយដើរលក់នំលក់អីអញ្ចឹងទៅ ហើយខ្ញុំនៅនេះហើយញ៉ុមទៅនៅចាក់អង្រែទៀត។

កៈ ចា៎!!

ខៈ ទៅនៅចាក់អង្រែទៅដើរលក់នំទៅដើរលក់ជ្រក់អីតាមផ្ទះគេ។

កៈ ចា៎!!អញ្ចឹងពេលមុនអ្នកមីងប្រាប់ថាម៉ែអ្នកមីងរកស៊ីលក់ជ្រក់មីងណោះ?

ខៈ ចា៎!!

កៈ ដល់ពេលបែកពីប៉ុល ពតហើយ ក៏នៅតែរកស៊ីលក់ជ្រក់ទៀត?

ខៈ បែកពីអាពតហើយ ចាំមើលយើងបែកពីអាពតហើយខ្ញុំចាប់ផ្ដើមលក់អន្សមដំឡូង!!

កៈ ចា៎!!

ខៈ នៅវត្តឈ្លូងលៀបនេះ ដូរអង្ករសំរូបយើងចាយលុយរៀតណាម!!

កៈ ហ៊ឺៗ!!

ខៈ យើងធ្វើអន្សមដំឡូងហា៎ អន្សមដំឡូងហ្នឹងទៅយកទៅដូរយើងងើបពីយប់ទៅយកទៅដូរទៅទៅដូរជាមួយពួកគាត់ កាលហ្នឹងជំនាន់ហ្នឹងគេហៅថារត់ពន្ធ។

កៈ ចា៎!!

ខៈ ហ្នឹងហើយ ជំនាន់យើងហ្នឹងគេហៅថារត់ពន្ធហើយញ៉ុមងើបទៅដូរនំដំឡូងហ្នឹងអញ្ចឹងជាមួយគេជាមួយឯងហ្នឹងអ៊ិចឹងទៅ!!នៅមុខវត្តឈ្លូងលៀបហ្នឹងទៅ!!

កៈ ហ៊ឺៗ!!

ខៈ ហើយដល់បន្ទាប់មក ពេលមកពីលក់នំលក់អីបានមករៀន ហើយអញ្ចឹងវារៀនអត់ទាន់គេទេ!!

កៈ ហ៊ឺៗ!អ៊ីចឹងវាពិបាកអ៊ិចឹងបានឈប់រៀនទៅមីងណោះ?

ខៈ ចា៎!!ព្រោះអីញ៉ុមម្ដាយមេម៉ាយចិញ្ចឹមកូនដល់ទៅ៤ ហើយម្ដាយគាត់ចាស់ជរាមួយទៀត។

កៈ ហ្ហ៎!!
ខៈ អញ្ចឹងអត់មានអ្នកណាជួយជ្រោងទេ!!
កៈ  ហើយបងប្រុសមឹងអត់ព្រមជួយដែរ?
ខៈ អត់ទេព្រោះគេរៀន !!
កៈ ហ្ហ៎!!
ខៈ  គេនៅរៀន!!
កៈ  សុទ្ធតែគេនៅរៀនទាំងអស់គ្នាហ្នឹង?
ខៈ អឺចឹងមានតែញ៉ុមមួយទេ!! ចា៎!! រៀន បងប្អូន៨នាក់រៀន៣។
កៈ ហ៊ឺ!!
ខៈ ញ៉ុមរៀនដែរតែញ៉ុមរៀនអត់បានជិតដល់ទេ។
កៈ
តាមពិតហា៎ពួកគាត់គួរតែដឹងគុណអ្នកមឹងអោយច្រើនហើយដោយសារអ្នកមឹងលះបង់ច្រើនសំរាប់គ្រួសារខ្លាំងណាស់!!
ខៈ ចា៎!!
កៈ  អត់បានរៀន តែពួកគាត់សុទ្ធតែបានរៀនទាំងអស់គ្នា!!
ខៈ  បានរៀន!!
កៈ  ហើយប្អូនបានធ្វើពេទ្យទៀត!!
ខៈ ចា៎!!
កៈ
គួរតែនឹកឃើញគុណបងស្រីដែលខំជួយនេះហិទៅអត់ចង់ស្គាល់បងប្អូនអត់ដែលមកលេងមកអីវិញ!!
ខៈ  ចា៎!!អត់ដែលទេ!!
កៈ  ចុះដល់ពេលប្អូនមឹងនៅជិតនេះបងអីមានទាក់ទងអីជាមួយអត់?
ខៈ  អត់ ដូចអត់មានទាក់ទងអីផង!!
កៈ  ដូចទាក់ទងមកអឺចឹងណាស់!!
ខៈ  អត់ដែលមកទេ មកពេលការកូនវាអាហ្នឹងមក។កៈ ហ៊ឺៗ!!ខៈ ចា៎!!
កៈ តែអត់មានទំនាស់អីណាអ្នកមឹងណោះ?
ខៈ  អត់មានទំនាស់អីទេ។
កៈ  ចំលែក!!

ខ៖  ចំលែក!!
ក៖ ហ្នឹងហើយ!!
ខ៖  ចំលែក ចំលែកមែន!!
ក៖ និយាយទៅរៀងៗខ្លួនម៉ងទៅធម្មតាអ្នកមីងមនុស្សត្រូវតែមានបងប្អូនដោយសារពេលចូលឆ្នាំពេលភ្ជុំអីអញ្ចឹតងទៅជួបជុំគ្នាលេងសើចសប្បាយណាស់មីងណាស់!!
ខ៖  អត់មានទេ ។
ក៖  ដល់ពេលរៀងៗខ្លួនអញ្ចឹងទៅចំឡែក។
ខ៖ ចំឡែក។
ក៖  តែអត់អីអ្នកមីងមានបងប្អូនភូមិស្រុកដែរមីងណោះ?
ខ៖  ចាំហ្នឹងហើយ!!
ក៖ ចាំដល់ពេលនៅពីក្មេងមកអញ្ចឹងណាស់ពេលមីងរៀនអញ្ចឹងមីងមានក្តីស្រម៉ៃថាចង់ធ្វើអីអត់?
ខ៖ មានដែរ!!
ក៖  ម៉េចវិញទៅមីង?
ខ៖ មានក្តីស្រម៉ៃមួយចង់ធ្វើដូចថាចង់ចាប់អាជីពអីមួយដូចថាអោយមានមុនរបរសំរាប់ខ្លួនឯងហាំ!!នឹកឃើញថាឪពុកយើងធ្វើដល់តែដុកទ័រ
អញ្ចឹងបើអត់ពីគាត់ទៅអោយមានអ្នកណាគេមួយតំណាងហាំ!!កូនទាំង៩ហ្នឹងហាំ!!តែអត់  អត់បានអាប្អូននោះមួយអញ្ចឹងហាំ!!
ក៖  អញ្ចឹងបានប្អូនពៅហ្នឹងធ្វើពេទ្យមួយដែរ?
ខ៖  ប្អូនទី៣!!
ក៖ ចាំ!!
ខ៖ ចាំ!!តែអើយដល់មកញុំមអត់មានបានរៀនសូត្រអីជ្រៅជ្រះអីនឹងគេទេ!!
ក៖ ចាំ!!តែមីងចង់មានមុខរបរអីមួយច្បាស់លាស់ដែរអឺចឹងទៅមីងណោះ?
ខ៖ ញុំមចង់មានរកអាជីពមួយអីអោយនឹងចឹងទៅថាកុំអោយវាហាត់ពេកហាំព្រោះថាយើងវាឆ្អែតហើយ ព្រោះថាវានឿយពេកហើយហាំ!!នឿយឆ្អែត ឆ្អែតនិយាយលែងចង់ចេញម៉ងហាំ!!
ក៖ ហ៊ីៗ!!

ខ៖ នឿយឆ្អែតហើយអត់មានថាជួបការសប្បាយទេសព្វថ្ងៃហ្នឹងហើយក៏ដោយ!!
ក៖ ហ៊ីៗ!!
ខ៖ តិចថាដែលបានដើរទៅណាបានស៊ីអីឆ្ងាញ់ចុះ!! សព្វថ្ងៃរកបានតែដោះបំណុលគេទេណាស់!!ពីរនាក់ប្តីប្រពន្ធ!!
ក៖ ហ៊ី!!
ខ៖ រាល់ថ្ងៃហ្នឹងហាំ!!គ្រាន់តែឥឡូវគ្រាន់តែបានរៀងស្រាលបន្តិចទេ!!បន្តិចទេ មិនច្រើនទេ បន្តិចទេ!!
ក៖ ចាំ!!
ខ៖ ចាំ ដូចកាលទៅណោះអញ្ចឹង ហ្អែងមិនឃើញញ៉ុមទៅណោះទេ មកទល់សព្វថ្ងៃញ៉ុមមានប្លែកទៅណា!!
ក៖ ចាំ!!
ខ៖ មនុស្សយើងបើមានលុយអាហ្នឹងវាប្លែកហើយជឿអត់?
ក៖ ហ្នឹងហើយ។
ខ៖ តែតែអត់លុយហើយអត់មានប្លែកទេវានៅតែក្រៀមអ៊ីចឹងវាគ្មានរីកទេ!!
ក៖ ចាំអ៊ីចឹងមីងពេលនៅពីក្មេងមកពេលបែកពីប៉ុល ពតហ្នឹងដើរលក់អន្សមដំឡូង?
ខ៖ ចាំ!!លក់អន្សមដំឡូង លក់ជ្រក់ញ៉ុមដើរដូរត្រើយកើតត្រើយអីណោះ លក់ជ្រក់ផ្លែថាវអីហ្នឹងដឹងកង់រហូតដល់ឆ្លងទៅដល់ត្រើយកើតហ្នូ!!ម្នាក់ឯងហាំ!!
ក៖ ធ្វើផ្អែប៉ូវ ឬក៏ជ្រក់ផ្លែថាវ?
ខ៖ ផ្អែប៉ូវ ជ្រក់ផ្លែថាវក៏មាន។
ក៖ អញ្ចឹងមីងអារបៀបធ្វើជ្រក់ផ្លែថាវហ្នឹងដូចតែធ្វើអារបៀបអាស្ពៃហ្នឹងដែរតើមីងហេ?
ខ៖ ចាំតែគ្រាន់តែចិតវា ច្របាច់វាជាមួយទឹកអំបិលអោយអស់ហាង។
ក៖ ហ្នឹងហើយ!!
ខ៖ ចាំ!!
ក៖ ចុះដល់ពេលគេធ្វើផ្អែប៉ូវវិញគេធ្វើម៉េចទៅ?
ខ៖ ធ្វើផ្អែប៉ូវយើងអត់មានធ្វើអីទាំងអស់ យើងគ្រាន់តែយកផ្អែប៉ូវ យើងពុះវាជា២ជា២ហើយយើងលាងវាអោយស្អាតហើយដាក់ត្រាំទឹកអំបិលហើយស្រង់វាហាលទេ។
ក៖ ហ្ហូតែប៉ុណ្ណឹងទេហេមីង?
ខ៖ ចាំហ្នឹងហើយ ហ្នឹងផ្អែប៉ូវប្រៃ។ក៖ ចាំ!ខ៖ បើយើងចង់ធ្វើផ្អែប៉ូវផ្អែម ផ្អែប៉ូវជូរអីអាហ្នឹងយើងត្រាំវាអោយអស់ជូរទៅអាហ្នឹងយើងយកមកប្រលាក់ស្ករ។

កៈ អាហ្នឹងយើងយកមកប្រលាក់តែទឹកស្គរទេអ្នកមីងណោះ?
ខៈ ចាំអាហ្នឹងប្រលាក់តែទឹកស្ករត្រាំតែទឹកស្ករទេណាស់!!
កៈ ដោយសារញ៉ុមឃើញនៅផ្សារអីវ៉ាន់មើលទៅគេលក់ស្រួយៗហើយស្រស់ៗ គេធ្វើម៉េចបានគេរក្សាមួយហ្នឹងបានអ្នកមីង?
ខៈ អើយអាហ្នឹងគេត្រាំទឹកខ្មេះ !!
កៈ ហ្ហ៎!!
ខៈ ត្រាំទឹកខ្មេះអញ្ចឹងទៅ!
កៈ ចិតភ្លាមដាក់ត្រាំទឹកខ្មេះយកតែម្តងឬក៏ហាលសិន?
ខៈ ហាលគេហាលសិន!!
កៈ ហើយត្រាំទឹកខ្មេះ?
ខៈ គេហាលអោយវាអស់ហាង!ចាំច្របាច់អោយអស់អានេះសិន ធម្មតាយើងច្របាច់ទៅយើងដាក់ចូលក្នុងទឹកខ្មេះវាមានជាតិស្រួយហើយ!!
កៈ ហ្ហ៎!!!
ខៈ ហ្នឹងហើយ!!
កៈ អញ្ចឹងត្រូវតែត្រាំទឹកខ្មេះជាដីរេចតែម្តង?
ខៈ ហ្នឹងហើយ។
កៈ ទឹកខ្មេះទឹកត្នោតយើងឬក៏ទឹកខ្មេះចេក?
ខៈ ទឹកខ្មេះយើងអាទឹកខ្មេះជូរអែម យើងកុំត្រាំទឹកខ្មេះបារាំង!!
កៈ ហ្ហ!!
ខៈ វាកាត់ច្រើនពេក!!
កៈ អញ្ចឹងអាទឹកខ្មេះទឹកត្នោតហ្នឹងមីងណោះ?
ខៈ ហ្នឹងហើយ។
កៈ ឆ្ងាញ់ណាស់ទឹកខ្មេះទឹកត្នោត ញ៉ុមណោះបានម្ទេសមកមួយហោប៉ាវហើយយកទៅត្រាំហើយ!!
ខៈ ត្រាំ!!
កៈ ហ្នឹងហើយមីង ហើយអើរ របៀបធ្វើ ដូចសារញ៉ុមចេះតែធ្វើអន្សមជ្រូក អន្សមចេក អន្សមខ្ទុរ ដល់ពេលអន្សមដំឡូងគេធ្វើម៉េចទៅមីង?
ខៈ គេឈូសដំឡូង !!
កៈ ចាំ!!

ខ៖ ដំឡូងឈើយើងហ្នឹង គេយកវាមកបក យកមកបកវាលាងទឹកអោយស្អាតហើយគេឈូសវា ឈូសវាឈូសអាដែកឈូសយើងធម្មតាហ្នឹង !!

ក៖ ចាំ!!

ខ៖ ឈូសសរសៃរៗអញ្ចឹងទៅ ហើយគេយកស្លឹកចេកមកវិចអញ្ចឹងទៅ ហើយដាក់ចេកវេចដូចយើងហ្នឹងធម្មតា!!

ក៖ តែមានលាយអង្ករទេហោ?

ខ៖ អត់មានលាយទេ លាយតែដូងទេ។

ក៖ លាយតែដូងហើយនឹងដាក់ចេកប្រឡោះកណ្តាលអីចឹតងទៅ?

ខ៖ ចាំ!!ហ្នឹងហើយ!!

ក៖ អើរតាមការពិតអត់សូវមានដែលអ្នកណាគេសូវធ្វើមួយហ្នឹងទេអ្នកមីងណាស់ឥឡូវណាស់!

ខ៖ ចាំ!! ប៉ុន្តែឆ្ងាញ់!!

ក៖ ហើយមីងម៉េចអត់ព្រមធ្វើអាហ្នឹងលក់ទៀតដោយសារធ្វើការហោ?

ខ៖ ធ្វើការ ហើយណាមួយយើងអត់មានដំឡូងអត់មានអីផងឥលូវនេះនោះ!!

ក៖ ហ្វ៊ូ!!

ខ៖ អត់មានដំឡូងផង!!

ក៖ ចាំ!!ធ្វើដំឡូងអីវ៉ាន់លុះត្រាតែដល់ពេលដែលទៅឆ្ងាយៗទៅស្រុកចំការ!! មួយហ្នឹងស្ងោរតើមីងហោ អត់ចំហុយទេណាមីងអាហ្នឹង?

ខ៖ ស្ងោរក៏បានចំហុយក៏បានប៉ុន្តែយល់ល្អស្ងោរវាឆាប់ឆ្អិនជាង!!

ក៖ ចាំតែចំហុយឆ្ងាញ់អ្នកមីងហោ?

ខ៖ ចងដូចគ្នា!!យើងចងខ្សែដូចគ្នាអត់អោយទឹកចូលដូចគ្នា!!

ក៖ ចាំ!!

ខ៖ ចាំ!!

ក៖ អញ្ចឹងពេលហ្នឹងរកស៊ីអីវ៉ាន់គ្រាន់បើដែរតើហោ ទាំង២នាក់ម៉ែជួយប្អូនជួយអី?

ខ៖ ពីរនាក់ម៉ែទៅងើបពីយប់អញ្ចឹងទៅធ្វើអញ្ចឹងទៅជឹកកង់យកទៅវត្តឈូងលៀបហ្នឹងទៅបណ្តើរកង់តាមក្រោយ ម៉ែដើរតាមក្រោយញ៉ុមដាក់កង់យកកទៅទៅ។

ក៖ ចាំ!!

ខ៖ យកទៅលក់អញ្ចឹងទៅ។

ក៖

ហឺៗ!!ចាំ!អញ្ចឹងអ្នកមីងចូលដល់ពេលអាហ្នឹងរៀនដល់ថ្នាក់ទី៣ក៏រកស៊ីរកអីជាមួយម៉ែអញ្ចឹងទៅ?ហើយដល់ពេលមីងចូលដល់ក្រុមគ្រួសារប្តីវិញម្តង

ការជាមួយនឹងលោកពូប្តីអ្នកមីងគាត់ឈ្មោះអីគេដែរ?

ខ៖ គ្រួសារញ៉ុមមុនមែន?

ក៖ អ្នកមីងមានស្វាមីពេលមុនដែរហេ?

ខ៖ ចាំ!!

ក៖ ឥឡូវនិយាយពីស្វាមីពេលមុន ស្វាមីពេលមុនគាត់ឈ្មោះអីគេវិញ?

ខ៖ ឈ្មោះធី។

ក៖ អីគេធីវិញ?

ខ៖ ហាង្ស វុទ្ធី!!

ក៖ ចាំឥឡូវគាត់រស់ឬក៏អនិច្ចាកម្ម?

ខ៖ គាត់នៅរស់តើ!!

ក៖ ហ្អាំអញ្ចឹងលែងគ្នាហើយមីងណោះ?

ខ៖ ចាំលែងគ្នា គាត់ទៅចោលតែម្តង!!

ក៖ ហ៊ឺយ៉ាប់ម៉ង!!

ខ៖ ញ៉ុមឆ្លងទន្លេ ញ៉ុមឆ្លងទន្លេហើយម៉ោង៥អិចឹងគេទៅបាត់ ទៅបាត់រហូតទៅ។

ក៖ ហើយអត់ តែឥឡូវដឹងថាដំណឹងនៅណាអីអត់?

ខ៖ នៅបាត់ដំបង។

ក៖ ចំហើយម៉េចទៅចោលប្រពន្ធអ៊ីចឹង?

ខ៖ ចាំ!!ញ៉ុមឆ្លងទន្លេហើយល្ងាចហ្នឹងអ៊ីចឹងចេញទៅបាត់ ទៅបាត់រហូតទល់តែសព្វថ្ងៃហ្នឹង!!

ក៖ ហើយអត់លែងគ្នាទេអ៊ីចឹង?

ខ៖ អត់មានឈ្លោះអត់មានទាស់អត់មានលែងគ្នាអីទេ!!

ក៖ ហ៊ឺៗ!!

ខ៖ តែទៅបាត់រហូតទល់សព្វថ្ងៃហ្នឹងមក គិតទៅ២៧ ២៨ឆ្នាំមកហើយ!!!

ក៖ មីងពេលហ្នឹងរៀបការអាយុប៉ុន្មាន?

ខ៖ ញ៉ុមការអាយុ១៩ឆ្នាំ។

ក៖ ហើយប៉ុន្មានឆ្នាំបានបែកគ្នា?

ខ៖ អើយ កូន កូន៣ ។
ក៖ ហើយទៅចោលកូនទាំង៣?
ខ៖ ចា៎ កូន៣កើតចុងក្រោយគេហ្នឹង។
ក៖ ហើយគាត់មានយកកូនទៅខ្លះទេ?
ខ៖ អត់មានទេ!!
ក៖ ហុីៗៗអីក៏ទំលាក់បន្ទុកអោយមកគេទាំងអស់ម្លេះ!!!
ខ៖ ញ៉ុមនៅគ្រប់គ្រងទាំងអស់!!ញ៉ុមនៅគ្រប់គ្រង!!
ក៖ ហើយចុះម៉ែក្មេកអីថាម៉េចទៅអញ្ចឹង?
ខ៖ ម៉ែក្មេកញ៉ុមអត់មានទេ គាត់ស្លាប់កាលពីអាពតដែរ!!
ក៖ អញ្ចឹងគាត់កំព្រាហេ?
ខ៖ ចា៎គាត់កំព្រាមានតែម្ដាយចុង!!
ក៖ ហុី!!ហើយបងប្អូនគាត់អីវ៉ាន់?
ខ៖ បងប្អូននៅជុំទាំងអស់ហ្នឹង នៅកោះធំ នៅចាក់អង្រែ នៅប្រាសាទ!
ក៖ ហើយចុះបងប្អូននិយាយថាម៉េចទៅមីងទៅចោលកូន៣?
ខ៖ គេហួសចិត្តតើ!!ហួសចិត្តហា៎!!
ក៖ គាត់អត់មានជំងឺអីណាហី?
ខ៖ អត់មានជំងឺអីគេទេ គ្រាន់តែថាមានបញ្ហាអញ្ចេះ ឪពុកក្មេកញ៉ុមបងថ្លៃញ៉ុមគេអោយតែញ៉ុមលែងទៅគេសុខចិត្តចិញ្ចឹមញ៉ុម ព្រោះអីប្ដីញ៉ុមហ្នឹងកំពូលមនុស្ស។
ក៖ កំពូលម៉េចទៅមីងបានដល់ថ្នាក់ហ្នឹង?
ខ៖ កំពូលមនុស្ស ខ្ញុំមិនដឹងដែរប៉ុន្តែអើរឪពុកក្មេកញ៉ុមថាអស់ទាស់រកលេខដាក់គ្មានហើយ!!
ក៖ ផឹកជក់ខូចម៉េចមីង?
ខ៖ ថាខូចម៉ងកំពូលមហាខូចស្រី!!
ក៖ ហ្វូអោយទៅទៅ!!
ខ៖ ហ្នឹងហើយ!!
ក៖ បើសិនជារឿងស្រីហ្នឹង!!
ខ៖ ហើយបើរឿងឪពុកក្មេកបងថ្លៃអីធានាចិញ្ចឹមញ៉ុមទាំងអស់ ប៉ុន្តែញ៉ុម ដូចយើងអត់ពីសាច់គេយើងអត់ទៅតោងតៀមគេធ្វើអី!!
ក៖ ចា៎!!

ខ៖ ចាំយើងវាមានចិត្តគិតអញ្ចឹងហាំ!!
ក៖ តាមពិតទៅហ្នឹងហាំដោយសារស្រីទេមីងណោះ?
ខ៖ ចាំទៅជាមួយស្រីតើ!!
ក៖ មនុស្សប្រុសអញ្ចឹងហិ!!
ខ៖ ញ៉ុមឆ្លងទន្លេហើយទៅបាត់អញ្ចឹងហិ!!
ក៖ ងាប់ហើយមិនឈឺទាស់ងាប់ហើយមីង?
ខ៖ ហ៊ឺញ៉ុមទាស់ប៊ិសងាប់!!
ក៖ មែន?
ខ៖ ចាំញ៉ុមទាស់ប៊ិសងាប់!!
ក៖ ញ៉ុមមិញនិយាយរឿងលែងទេណាស់ ដល់ពេលនេះមែន!!
ខ៖ ចាំ!!ទាស់ ញ៉ុមប៊ិសងាប់នៅពេទ្យតាខ្មៅតើ!!ពេទ្យជ័យជំនះគេបញ្ជូនទៅសាលហើយតើ!!
ក៖ ចំ!!ពេលហ្នឹងម៉េចមីងពិបាកចិត្តខ្លាំងពេកមីងហោ?
ខ៖ អើរចាំមើលហាំបើនិយាយទៅប្រវត្តិញ៉ុមវាកំសត់កំសត់ថាគ្មានអ្នកណាកំសត់ដូចទេមើលទៅហ្ន៎!!ប៉ុន្តែយើងមិនបាច់និយាយអោយវែងឆ្ងាយទេ!!
ក៖ ហ៊ឺៗ!!
ខ៖ អើយទៅចោលញ៉ុមបាត់អញ្ចឹងហាំធម្មតាយើងនៅជាមួយបងប្អូនយើងមានប្តីហើយហើយយើងនៅជាមួយប្អូនៗលីវនៅអត់ដែលស្រួលទេមែនអត់?អត់ដែលនៅស្រួលទេ ហើយញ៉ុមហាំកូនបាន៦បាន៥ខែញ៉ុមចុះទៅវៃមែងហាំ ចុះទៅដេញត្រីហាំ!!
ក៖ ចំ!!
ខ៖ ចុះទៅដេញត្រីហាំញ៉ុមដាក់ដេញត្រីយកមងទៅដាក់យកត្រីទៅចិញ្ចឹមកូនអញ្ចឹងទៅចុះកូនវានៅទូចហើយយើងនៅស៊ីដោយសារគេយើងលេបអត់រួចទេណាស់ គេថាមួយម៉ាត់មកវាឆ្អែតហើយណាស់!!ពេលដែលស៊ីបាយគឺទឹកភ្នែក អញ្ចឹងហាំហើយដល់តែពេលហើយអញ្ចឹងទៅក៏លែងខ្វល់លែងអីហើយញ៉ុមដល់ឆ្លងទន្លេហើយញ៉ុមដល់អាកូនក្រោយហ្នឹង ឆ្លងទន្លេហើយទៅបាត់អញ្ចឹងហិ!! គេប្រាប់ម៉ាក់ញ៉ុមថាម៉ាក់ៗម៉ាក់ឯងមើលប្រពន្ធញ៉ុមផងញ៉ុមទៅដើរស៊ីឈ្នួលបោកស្រូវអោយគេ។
ក៖ ប្តីមុនហ្នឹងហោ?
ខ៖ ចាំ!!ដល់គេថាគេទៅហ្នឹងគេទៅបាត់ទៅ ទៅបាត់ប្រហែលជាម៉ោង៨ព្រឹកម៉ោង៨ព្រឹកឮសូរគេស្រែកថាហ៊ឺអាធីគេទៅបាត់ហើយ យកតាំងពីម៉ាញ៉េគេទៅទៀត។

កៈ ហ៊ឺៗ!
ខៈ  យកតាំងពីម៉ាញ៉េយកតាំងពីបារគេទៅទៀតថាអញ្ចឹងហា៎!!  ហើយយើងនៅលើភ្លើងហ្នំ!! យើងដូចរាងធឹប ដូចរាងធឹបនៅក្នុងខ្លួន ធឹបក្នុងខ្លួនចាប់ធ្លាក់ឈាមរហូត ចាប់ធ្លាក់ឈាមរហូត បាតដៃទទេអត់មានលុយអីមួយរៀល
ម្ដាយញ៉ុមណោះគាត់ពិបាកចិត្តពេកគាត់ដើរចងការគេយកញ៉ុមទៅពេទ្យ
ធ្លាក់ឈាមរហូតដល់ពេលគេថាញ៉ុមហ្នឹងប្រហែលជាធ្លាក់ឈាមអត់អស់ទេ
គេបារដាច់ស្បូនមនុស្សស្រីយើង ដាច់ស្បូនមួយដុំដូចសាច់គោអញ្ចឹង ហើយគេថាកំទេចយើងអត់ចាប់អារម្មណ៍ហា៎!!
កៈ តាមពិតស្បូនសោះ?
ខៈ ចា៎!!ស្បូនដាច់សាច់ស្បូនហា៎!! ដំបៅហូរ ហូរ ថាស្អុយអត់មានអ្នកណាទៅជិតញ៉ុមកើតទេ ស្អុយអត់មានអ្នកណាទៅជិតទេ!!ដល់តែពេលហើយញ៉ុមចាប់ហើមខ្លួនហើមៗៗៗៗឡើងលឿងសាច់ឡើងលឿងម៉ងអត់មានឈាមទេ!!
ហើមហើយដល់ពេលនេះបញ្ជូនទៅពេទ្យជ័យជំនះហ្នឹង
ទៅនិយាយទៅដឹងគុណដុកទ័រហ្នឹងដែរ ស្រីៗហ្នឹង ពេទ្យស្រីហ្នឹង មិនដឹងជាគាត់ទៅដល់ណាអស់ទេ!!
កៈ ចា៎!!
ខៈ  ទៅដល់គាត់ស្រវៃស្រវ៉ា ទៅមុនដំបូងគាត់សួររកលុយ ហើយម្ដាយញ៉ុមអត់ទាន់ទៅទេ គាត់ដើររកលុយគេនៅណោះហា៎!!
កៈ ហ៊ឺ!!
ខៈ  ដើររកនៅដើររកលុយគេនៅណោះអោយតែអ្នកម៉ូតូឌុបហ្នឹងជូនញ៉ុមទៅដល់ពេទ្យណោះ ម៉ែនៅណោះកូនក៏នៅណោះដែរកូនញ៉ុមអាក្រោយនេះ
ញ៉ុមទៅដល់ណោះមុនដល់ហើយថាចាំនិយាយគ្នារឿងលុយសិន
គេទុកយើងចោលសិនអាហ្នឹងហា៎!!កៈ ហ៊ឺៗ!!ខៈ
ដល់តែពេលហើយបានម្ដាយធំហ្នឹងគាត់ថាឥឡូវមីអូនឯងមើលវាសិនទៅ
ព្រោះគ្នាវាឈឺធ្ងន់ណាស់ ដល់ហើយគេក៏មើល
មើលហើយបានម្ដាយញ៉ុមទៅទាន់ហ្នឹងទៅទាន់ចងការគេបាន
កាលហ្នឹងលុយជំនាន់កាលហ្នឹងបាន៧០០០ ៨០០០ គេទារ៧០០០ គេទារ៧០០០ណាស់!!
កៈ ចា៎!!

ខ៖
ដល់ពេលហើយម៉ែញ៉ុមហ្នឹងគាត់ថាអោយគេក៏អោយទៅអោយគេយកចិត្តទុកដាក់បន្តិចទៅ!! ក៏មើលញ៉ុមនៅហ្នឹងពេទ្យជ័យជំនះហ្នឹងទៅ!!ញ៉ុមចាប់ហើមហ្នឹងស្អុយខ្លួនហ្នឹងគេមកលាងរបួសមកលាងអីអោយយើងអញ្ចឹង!!
ក៖ ហ៊ីៗ!!
ខ៖ តែអានេះគេថាដូចថាសំណាងយើងអញ្ចឹងឬមួយក៏យ៉ាងម៉េចទេណាស់!!
ក៖ ចាំ!!
ខ៖ ញ៉ុមដេកពេទ្យបានតែ៣ថ្ងៃទេញ៉ុមសុំគេចេញមកវិញ កាលហ្នឹងពលករស្លាប់ច្រើនពេក!!
ក៖ ម៉េចវិញទៅមីងពលករមកពីណា?
ខ៖ ពលករកាប់ព្រៃនោះ ពលករគេហៅករ!!
ក៖ ហ្ហ៎គេហៅករ៥ហ្ហ៎!!
ខ៖ ចាំ!!ហើយពេលជ័យជំនះពេលហ្នឹងពីឆ្នាំ៩១(១៩៩១)ពេលហ្នឹងអត់ទាន់ស្អាតទេ បង្កួចអីវ៉ាន់ហាំ លលកខ្មោចមកទុំនៅអញ្ចឹងហិ!!ហើយយើងយប់ឡើងវាងងឹត។
ក៖ អូយខ្លាចណាស់មីង!!
ខ៖ យំទុំមាត់បង្អួចហាំ!!ហើយម៉ែញ៉ុមដេកយំរាល់យំ ហើយគាត់អត់ហ៊ានសំរានទេ!!
ក៖ ហ៊ី!
ខ៖
យប់ឡើងគាត់អង្គុយទឹកភ្នែករហាមរហូតណាអត់លុយណាកូនឈឺណាចៅមើលទៅនេះហាង ហើយដល់ពេលហើយញ៉ុមដេកពេទ្យញ៉ុមថាកូនអើយអញ្ចេះទៅ
នៅដេកពេទ្យហ្នឹងនៅដេកយូរអត់បានទេ
ទៅផ្ទះទៅទ្រាំទៅយកថ្នាំពេទ្យអីយកទៅផឹកនៅផ្ទះទៅ
ញ៉ុមគេចេញពីពេទ្យដេកបាន៣ថ្ងៃញ៉ុមហើមខ្លួនពេទ្យគេអត់អោយចេញមកណា
ប៉ុន្តែយើងនៅអត់កើត យើងនឹកឃើញថាយើងងាប់រស់នៅផ្ទះទៅវាស្រួល!!
ក៖ ហ៊ីៗ!!
ខ៖ ចុះកូនមួយវានៅផ្ទះណោះទៀត!!
ក៖ កូនទូចទឹមតែកើតហ្នឹងហេ?
ខ៖ កូនញ៉ុមអាទូចហ្នឹងយកទៅណោះហើយ!!
ក៖ ហ្ហ៎!!
ខ៖ ចាំ!! តែកូននៅផ្ទះណោះទៀតផ្ញើរប្អូននេះ ផ្ញើរប្អូនពៅហ្នឹង!!

ក៖ ចាំ!!
ខ៖
ដល់ពេលដែលញ៉ុមចេញមកពីពេទ្យវិញកូនញ៉ុមនៅផ្ទះណោះវារុំយកកៅស៊ូរុំម៉េចទេដៃនេះឡើងដាច់ទៀត ម្ដាយមីងអត់មានមើល អត់មានមើលក្មួយទេ!!
ក៖ អូយ!!ហើយអាយុប៉ុន្មានយកកៅស៊ូកងលេងហ្នឹងធំហើយមីងហេ?
ខ៖ កូនញ៉ុមមេហ្នឹង៣ឆ្នាំ។
ក៖ ហ៊ីហើយលេងឡើងដាច់ដៃ?
ខ៖ ចាំ!!វាដាច់ថាទៅវានៅតែឆ្អឹងអញ្ចេកវានៅអានេះសាច់អានេះឆ្អឹងអានេះរឹតកៅស៊ូហាំ!!
ក៖ ហ៊ី!!
ខ៖
ដល់ញ៉ុមចេញពីពេទ្យញ៉ុមឃើញតើ!!ញ៉ុមឃើញអញ្ចឹងទៅបានម៉ែញ៉ុមគាត់យកអាចុងឡាមហ្នឹងឆ្កិះ !!!
ក៖ កៅស៊ូ!
ខ៖ កាត់អាកៅស៊ូចេញទៅហាំ!!
ក៖ ហ៊ី!!
ខ៖ មើលទៅបាន!!
ក៖ ជាទៅ!!
ខ៖ បានជាវិញទៅ ចាំ!!
ក៖ ធម្មតាគាត់អត់បានមើលជិតដល់អ៊ីចឹងទៅមីងណោះ?
ខ៖ ចាំ!!ហ្នឹងហើយ។
ក៖ ចាំហើយអញ្ចឹងក៏ជាអីវ៉ាន់មកនៅផ្ទះធម្មតាទៅ?
ខ៖ ហ្នឹងហើយញ៉ុមជានៅផ្ទះធម្មតា ញ៉ុមអត់មានអីហូបទេ។
ក៖ ហ៊ីៗ!!
ខ៖ ហូបបាយមួយដុំអញ្ចឹងទៅហូបជាមួយទឹកកក។
ក៖ ហើយម៉េចទៅហូបបាយជាមួយទឹកកកវិញ?
ខ៖ ទឹកកកឈូសហាំ!!
ក៖ ហ៊ី!!!

ខ៖ ចុះបើគេអត់អោយយើងហូបជាមួយអីទាំងអស់ គេអោយយើងហូបជាមួយចេកហ្នឹង ហើយយើងហូបចេកវាអត់កើត បបរហូបជាមួយចេក អីចឹងទឹកកកឈូសយើងផ្អែមៗហ្នឹង យើងសុខចិត្តហូបអញ្ចឹងទៅ។

ក៖ ចាំ!!

ខ៖ បានហូបកើត!!

ក៖ ហ៊ី ហើយអញ្ចឹងប្ដីទៅចោលឡើងបាត់ឈឹងម៉ងអញ្ចឹង?

ខ៖ ទៅបាត់ឈឹងរហូតទល់សព្វថ្ងៃញ៉ុមមានប៉ាវាហ្នឹងទៀត!!

ក៖ គាត់អត់មកអើតសោះ?

ខ៖ អត់រហូតទល់សព្វថ្ងៃហ្នឹង កូនការអស់ហើយ ៣ការអស់ហើយអត់មានមកអើតទេ។

ក៖ ហើយមីងទៅប្រាប់អីអត់?

ខ៖ ញ៉ុមអត់ទៅប្រាប់។

ក៖ ហ៊ីទៅអោយបាត់ម៉ងទៅ!!

ខ៖ ចាំ!!

ក៖ ញ៉ុមស្អប់ពេកខូចណាស់!!

ខ៖ អត់ប្រាប់អត់ប្រាប់ទេ!!

ក៖ តែពេលហ្នឹងចូលស្ដីដណ្ដឹងការអីត្រឹមត្រូវតើមីងហោ?

ខ៖ ចាំស្ដីដណ្ដឹងការត្រឹមត្រូវតើ!!

ក៖ ហើយពេលហ្នឹងគេការគេអោយជំនូនអីអត់?

ខ៖ គេហែរជំនូន កាលហ្នឹងថ្លៃណាស់ជំនាន់ហ្នឹង ថ្លៃផ្ទះញ៉ុម២០០ហាំ!!

ក៖ ចាំ!!

ខ៖ ថ្លៃទឹកដោះ២០០លុយខ្មែរយើងហ្នឹង!!

ក៖ ចាំ!!

ខ៖ ថ្លៃណាស់!!

ក៖ ឆ្នាំប៉ុន្មានមីងរៀបការ?

ខ៖ ញ៉ុមឆ្នាំ៨៧(១៩៨៧)។

ក៖ ហ្ហំមកណោះដែរហើយហ្នឹង បានបែកប៉ុល ពតមកបាន៧ ៨ឆ្នាំដែរហើយហ្នឹង!!

ខ៖ ចាំញ៉ុមការឆ្នាំ៨៧(១៩៨៧)ហ្នឹង!!

ក៖ ចាំ ហើយជួបគ្នាជាមួយពូដំបូងម៉េចដែរមីង?គាត់អត់អីណាហី គាត់ត្រឹមត្រូវស្រួលបួលតើហី?

ខ៖ ការពិតទៅមនុស្សគាត់ហ្នឹង មិនអីអាក្រក់ណាស់ណាអីពេកទេតែគ្រាន់តែថាខូចតែប៉ុណ្ណឹង!!

ក៖ ខូចតែរឿងស្រីតែប៉ុណ្ណឹង?

ខ៖ ខូចតែរឿងស្រីហើយហ្នឹងភូតភរតែប៉ុណ្ណឹង។

ក៖ តែអ្នកមីងមនុស្សហ៎ាសុខចិត្តអោយខូចអោយផឹកស្រាអោយជក់បារីអីវិញហ៎ា តែខូចរឿងស្រីហើយភូតភរអញ្ចឹងណាស់ !!

ខ៖ ហ្នឹងហើយ!!

ក៖ ក្នុងផ្ទះគឺអត់មានសុភមង្គលទេ!!

ខ៖ ដូចថាអើរកូនមួយទៅបាត់ កូនមួយទៅបាត់ !!

ក៖ ហ៊ឺៗ!!

ខ៖ ហើយម្ដាយញ៉ុម ញ៉ុមថាដាច់ខាតញ៉ុមអត់យកវិញទេណាស់ តាមម៉ែញ៉ុមថាអញ្ចេកកូនអើយទ្រាំទៅ ញ៉ុមថាអត់ចង់ទេមួយជាពីរជាបីហ៎ាមនុស្សស្រីយើងហ៎ា!!

ក៖ ចា៎!!

ខ៖ ចង់តែមួយហើយហ្នឹងមួយទេ គាត់ថាកូនឯងគិតមើលប៉ុនប្រហែលសត្វព្រៃហ៎ា គេទាក់មកគេផ្សុំងមកគេបង្ហាត់អោយស្ដាប់ភាសាមនុស្សបានចុះកូនឯងទំរាំតែមនុស្សកូនឯង ចេះតែផ្សុំងទៅ!!

ក៖ តែផ្សុំងមិនបាន!!

ខ៖ ឥឡូវផ្សុំងម៉េចទៀត!!គាត់អត់ស្ដាប់ផងហ្នឹងគាត់និយាយអីចឹងហ៎ា!!

ក៖ ជួបគ្នាដំបូងនៅណាមីងពេល បានស្រលាញ់គ្នា?

ខ៖ ជួបគ្នាញ៉ុមអត់មានបានអីទេ ពីនាក់ប្ដីប្រពន្ធញ៉ុមហ្នឹងអត់មានបានស្គាល់គ្នាទេ ដូចចាប់ភ្ជុលម៉ងហ្នឹងហ៎ា!!

ក៖ អញ្ចឹងម៉ែចាប់ភ្ជុលទេអញ្ចឹង?

ខ៖ បើការពិតទៅញ៉ុមនៅលក់ឥវ៉ាន់នៅផ្សារឈូងលៀបនេះអញ្ចឹងញ៉ុមលក់បង្អែមញ៉ុមលក់អីអញ្ចឹងដូចញ៉ុមនិយាយហូរហែរមកអញ្ចឹងមកហ្នឹង!!

ក៖ ចា៎!!

ខ៖ ដល់ពេលហើយគេឃើញញ៉ុមនៅលក់នៅហ្នឹងតើ!!

ក៖ ហ៊ឺៗ!!!

ខ៖ មុនដំបូងគេឃើញញ៉ុមមូលជើងខោរែកទឹកស្រោចបន្លែ ញ៉ុមស្រោចបន្លែមែន ញ៉ុមមកពីលក់ញ៉ុមស្រោចបន្លែហា៎ ស្រោចបន្លែ បន្លែញ៉ុម២០ ៣០រងញ៉ុមដាំខ្លួនឯងហា៎!!
ក៖ ហូ ឡូយទៀត!!
ខ៖ ហើយ ចា៎!! ញ៉ុមចេះតែដាំអញ្ចឹងទៅញ៉ុមទៅរែកទឹកស្រោចពីទន្លេមកស្រោចហា៎!!ក៖ ហ៊ីៗ!!ខ៖ ហើយដល់ហើយគេថាគេឃើញញ៉ុមនៅស្រោចរែកទឹកនៅហ្នឹងស្រោចបន្លែហ្នឹង!!
ក៖ ក៏ឃើញស្រលាញ់ហ្នឹងទៅ!!
ខ៖ ចា៎ក៏ឃើញស្រលាញ់ទៅគេមកស្ដីទៅ។
ក៖ ចា៎ អញ្ចឹងអ្នកមីងដល់ពេលលោកពូទៅបាត់អញ្ចឹងទៅដល់ប៉ុន្មានឆ្នាំក្រោយទើបអ្នកមីងមានលោកពូក្រោយមួយទៀត?
ខ៖ កូនញ៉ុមអាទី៣ហ្នឹង៩ឆ្នាំ។
ក៖ ហ្នំតែកូន៣នាក់ជាមួយពូមុនឈ្មោះអីគេខ្លះកូន?
ខ៖ ឈ្មោះអើយសុជាតិ ពិដោរ បញ្ញា។
ក៖ សុជាតិ ពិដោរ បញ្ញា?
ខ៖ ចា៎!!
ក៖ ហ៊ឺឈ្មោះពិរោះៗទៀត ហើយកូនប្រុសប៉ុន្មានស្រីប៉ុន្មានអ្នកមីង?
ខ៖ ញ៉ុមសព្វថ្ងៃហ្នឹងកូនស្រីតែមួយទេ!!
ក៖ ហើយកូនប្រុស២?
ខ៖ ប្រុស៣។
ក៖ ប្រុស៣។
ខ៖ អាហ្នឹងជាមួយពូមួយហា៎!!
ក៖ ហ្នំជាមួយពូខាងក្រោយមានកូនមួយដែរហេ?
ខ៖ ចា៎មួយមកអង្គុយមិញហ្នឹង!!
ក៖ចា៎!!
ខ៖ អាពៅមិញហ្នឹង!!
ក៖ ប៉ុនណាណីហើយហ្នឹង!!
ខ៖ ចា៎!!
ក៖ អូយលឿនម្ល៉េះ!!
ខ៖ ហ្នឹងឈប់រៀនហើយ!!

កះ ហើយម៉េចទៅអោយឈប់រៀនវិញអ្នកមីង?
ខះ អើយវាគ្រុនពោះរៀន ដល់គ្រុនពោះរៀនទៅវារៀនចាញ់គេវាឈប់ទៅ ហើយណាមួយវាអញ្ចេកញ៉ុមនិយាយត្រង់ការពិតហាំ ញ៉ុមនិយាយអត់មានលាក់អត់មានលៀមទេ យើងជីវភាពយើងវាខ្វះខាតដល់កូនវាត្រូវការលុយទៅរៀនដល់យើងខ្វះខាតអញ្ចឹងដល់ពេលវាទៅវាចេះតែមើលមាត់គេអញ្ចឹងទៅវាអត់ទៅវាខ្មាសគេអញ្ចឹងទៅណាស់!!
កះ ហ្ហ៎!!
ខះ ដល់ហើយប៉ាវាថាតាមដំនើរទៅអញ្ចឹងហាំ!!
កះ ឥឡូវធ្វើអីគេហើយអាអូន?
ខះ អាអូនវាអត់ទាន់មានធ្វើអីគេទេ!!
កះ នៅផ្ទះអញ្ចឹង!!
ខះ ឥឡូវញ៉ុមកំពុងតែថាចង់យកទៅដាក់នៅមណ្ឌល ហើយយើងមិនដឹងមណ្ឌលកន្លែងណាបើយើងវាអត់មានស្គាល់អត់មានអីសោះ វាចេះតែទារទៅដែរ ។
កះ ហ្នឹងហើយ!!
ខះ វាថាវាចង់មានជំនាញអីរបស់វាមួយ!!
កះ ហ្នឹងមួយហ្នឹងល្អ!!
ខះ វា វានិយាយអ៊ិចឹងហាំ!! វាថាម៉ែឯងមើលមានកន្លែងណា យកវាទៅដាក់នៅមណ្ឌលកុមារកំព្រាទៅលោរញ៉ុមមានជំនាញអីមួយ។
កះ ហ្នឹងហើយ។
ខះ តែញ៉ុមវាអត់មានខ្សែស្រឡាយអីដឹង យើងអត់ដឹង!!
កះ ញ៉ុមអត់ដឹងពីមួយហ្នឹងដែរហ្នឹង អត់ដែលដឹងពីអ្នកណាគេ ហ្នឹងបើសិនចាំមើលបើមានចាំប្រាប់។
ខះ ចាំ!!
កះ ចាំ!!
ខះ ហើយបើសិនជានៅនេះញ៉ុមខ្លាចតែកូនវាខូច។
កះ ហ្នឹងហើយឮថាគ្រប់កន្លែងសុទ្ធតែជក់ថ្នាំមីងណាស់!!
ខះ ព្រោះអីនៅកន្លែងនេះ ម្លុកកន្លែងនេះញ៉ុមខ្លាចណាស់។
កះ ម៉េចវិញទៅមីង?

ខ៖ នៅម្លុកកន្លែងនេះវាមានអ្នកជក់វាមានអ្នកផឹក វាមានអ្នកលេងអញ្ចឹងទៅណាស់ ហើយក្មេងកាលណាវាដើរជាមួយអ្នកជក់វាជក់ហើយ
ដើរជាមួយអ្នកផឹកវាផឹកហើយអញ្ចឹងញ៉ុមអត់ចង់អោយកូនទៅកន្លែងហ្នឹងទេ!!
ក៖ ហ៊ឺ!!
ខ៖
តែគ្រាន់តែថាសព្វថ្ងៃហ្នឹងវាដូចថាខ្វះខាតវាដូចថាខ្វះខាតមែនទែនម៉ងហាំ!!មិនមែនខ្វះខាតលេងៗទេណាស់!!
ក៖ ចាំ!!
ខ៖ អញ្ចឹងញ៉ុមជួយកូនវាអត់ទាន់កើត។
ក៖
ញ៉ុមសង្ឃឹមថាពេលអង្គការនោះគេមកជួយធ្វើរបសត្វធ្វើអីអ្នកមីងអាចមានជីវភាពគ្រាន់បើអញ្ចឹងអ្នកមីងហាំ!!
ខ៖ ហ្នឹងហើយចាំ!!
ក៖ សង្ឃឹមថាមួយហ្នឹង ហើយមីងខំប្រឹង!!
ខ៖ ចាំ!!
ក៖ ចាំហ្នឹងហើយ ញ៉ុមដឹងអីវ៉ាន់អិចឹងញ៉ុមចេះតែចែកចាយតគ្នាទៅមីងណាស់!!
ខ៖ ចាំ!!
ក៖
ដោយសារទោះតែញ៉ុមមិនមានអីអោយមីងឬក៏អោយទៅអ្នកផ្សេងទៀតប៉ុន្តែញ៉ុមអានាំពាក្យពីណាពីណីមកអោយចែកចាយអោយគ្នាដឹងអញ្ចឹងទៅអ្នកមីងហាំ!!!
ខ៖ ចាំ!!
ក៖
ចាំអញ្ចឹងមីងពេលបែកពីពូណោះបាន៩ឆ្នាំហើយបានបានរៀបការជាមួយពូខាងក្រោយហេ?
ខ៖ អើយញ៉ុមបែកពីប៉ាវាហ្នឹងកូនញ៉ុមទី៣អាយុបាន៩ឆ្នាំហ្នឹងបានញ៉ុមបានជួបប៉ាវាក្រោយនេះ!!
ក៖ ចាំ!!ហ្នឹងហើយ ជួបគ្នានៅណាវិញមីងប្តីក្រោយ?
ខ៖ គ្រួសារក្រោយញ៉ុមនៅហ្នឹងដែរ។
ក៖ ហ្ហ៎នៅជិតនេះដែរទេហេ?
ខ៖ នៅជិតគ្នាហ្នឹង!!

កៈ តែអើរមុនមកអត់ដែលមានទំនាក់ទំនងអីជាមួយគ្នាទេ?
ខៈ អត់ដែលទេ ។
កៈ  អត់ដែលទេ ដល់ពេលនេះទៅស្រលាញ់គ្នាអញ្ចឹងទៅមីងណោះ?
ខៈ  ចាំ!!
កៈ  ចាំពូក្រោយឈ្មោះអីគេវិញ?
ខៈ ឈ្មោះ សុង ហេង។
កៈ  សុង ហេង?
ខៈ ចាំ!!!
កៈ  ចាំមីងពេលមុនតាមពិតពេលមុនទៅវិហារមីងធ្លាប់មានកូនភ្លោះមែណទេ?តែរលូតហីអត់?
ខៈ  រលូត!!
កៈ  ហ្នឹងហើយ!!
ខៈ  រលូត!!
កៈ  ញុំមចាំ ពេលហ្នឹងមីងប្រាប់ញុំមថា!!
ខៈ ហ្នឹងហើយ!!
កៈ  មានកូនភ្លោះទៀត។
ខៈ  មានកូនភ្លោះ!!
កៈ តែរលូត!!
ខៈ រលូតអត់នៅកូនស្រីទៀតហាំ!!
កៈ
ចាំ!!ហ្នឹងហើយមីងប្រាប់ដូចមីប្រាប់ញុំមឥឡូវហ្នឹងអញ្ចឹងណាស់ញុំមចាំទាំងអស់!!ហ្នឹងហើយ!!
ខៈ  ស្រី!!
កៈ  តែដល់ពេលរលូតហ្នឹងហើយបានមានអាអូនក្រោយទៀតឬក៏អីដែរ ឬក៏មានមុន?
ខៈ  អើយការពិតទៅញុំមមានមុនអាមួយនេះមិញហ្នឹងមានមួយតែអត់នៅដែរ!!
កៈ ចាំ!!
ខៈ  តែអត់នៅដែរកូនស្រីដែរ។
កៈ ចាំ!!
ខៈ បាន២ខែវាទៅវិញទៅហ្នឹងបានមកទុំពោះបាន២ខែទេណាស់ ។កៈ ចាំ!!ខៈ ដល់ពេលទៅវិញទៅបានមកអានេះ!!
កៈ ចាំ!!

ខ៖ នៅអាមួយពៅមិញហ្នឹង ដល់ពេលញ៉ុមមានអាមួយពៅហ្នឹងបានប៉ុន្មានឆ្នាំបានញ៉ុមមានកូនភ្លោះហ្នឹង!!
ក៖ ហ្អ៎ហ្នឹងហើយ!!
ខ៖ បានអត់នៅហ្នឹង!!
ក៖ អាអូនពៅមិញក្រោយហ្នឹងឈ្មោះអីគេ?
ខ៖ ឈ្មោះ ប៊ុនណេង។
ក៖ សុង ប៊ុនណេង?
ខ៖ ហេង ប៊ុនណេង។
ក៖ ហេង ប៊ុនណេង ចាំ ឥឡូវឈប់រៀនដែរហើយ!!
ខ៖ ឈប់ហើយ។
ក៖ ហើយមីងសំរាប់នេះហ្អ៎ ដំបូងជួបគ្នាជាមួយពូក្រោយម៉េចដែរបានចាប់ផ្ដើមស្រលាញ់ទំនាក់ទំនងគ្នាអញ្ចឹងហាំ មើលថៃគ្នាអញ្ចឹងណាស់?
ខ៖ ញ៉ុមហើយគាត់ដូចអត់មានបញ្ហាអីផង គ្រាន់តែអត់ចាប់អារម្មណ៍ថាគេស្រលាញ់យើង ព្រោះគិតថាយើងដល់មេម៉ាយកូនបី យើងចាស់គេក្មេង!!
ក៖ តែគាត់កំលោះតើមីងហេ?
ខ៖ គាត់កំលោះ!!
ក៖ ចាំ ពូឥឡូវអាយុប៉ុន្មានហើយ?
ខ៖ គាត់អាយុ៣៧ហើយ។
ក៖ តែមីងបង!!
ខ៖ ចាំ!!
ក៖ តែមិនបញ្ហាអោយតែស្រលាញ់គ្នា!!
ខ៖ ញ៉ុមបង១៥ឆ្នាំហេ?
ក៖ អត់បញ្ហាមីងសម័យឥឡូវនោះអោយតែស្រលាញ់គ្នា កុំខ្វល់ ញ៉ុមពេលខ្លះ!! អូខេអញ្ចឹងមីងដំបូងគាត់ម៉េចបានមកចង់ចូលស្ដីដណ្ដឹងមីង?ម៉េចដែរ?
ខ៖ មុនដំបូងមកញ៉ុមក៏អត់ចាប់អារម្មណ៍ដែរនិយាយលេងសើចជាមួយម្ដាយគាត់ហ្នឹងហាំ កាលហ្នឹងគាត់អញ្ចេកគាត់មានទំនាក់ទំនងអីជាមួយស្រីទៀត ដល់ហើយស្រីហ្នឹងគេបោកគាត់ហាំ មិនថាស្រីហ្នឹងគាត់មានអីអោយគេបោកគាត់ទេ គាត់ក្រ!!
ក៖ ចាំ!!

ខ៖ ម្តាយគាត់ក្រដែរ ម្តាយគាត់ចាស់ដែរគ្មានអ្វីអោយគេបោកទេតែប៉ុនគាត់គេបោកចិត្តហាំ គាត់ឈឺចិត្តហាំ!!

ក៖ ហ្នឹងហើយ!!

ខ៖ ព្រោះមនុស្សគាត់មនុស្សល្អមនុស្សត្រង់។

ក៖ ឈឺចិត្តពិបាកណាស់អ្នកមីងហាំ!!!

ខ៖ ចាំ!!ដល់ហើយគេបោកចិត្តគាត់អញ្ចឹងទៅ ហើយខ្ញុំក៏ចេះតែនិយាយលេងហើយម្តាយគាត់ក៏ចេះតែយំរាល់ថ្ងៃ ម្តាយគាត់ហាំ!!

ក៖ ហ៊ឺៗ!!

ខ៖ គេចេះតែចាក់ចំរៀងចាក់អីអោយោស្តាប់អញ្ចឹងទៅគាត់ថាហ៊ីកុំចាក់ចំរៀងហ្នឹង គាត់ឮស្មូរបទហ្នឹងគាត់ចង់ក្អួតឈាមគាត់អានិតកូនគាត់គាត់និយាយអីចឹងហាំ!!

ក៖ ហ៊ឺ!!

ខ៖ ហើយញ៉ុម ញ៉ុមចេះតែនិយាយបង្អប់លេងទេ ញ៉ុមអត់មានបំណងអីទេ!!

ក៖ ហ្នឹងហើយ !!

ខ៖ អ៊ំហ្នឹង!!

ក៖ មិននឹកស្មានអីចឹងទៅហេ?

ខ៖ ចាំមិននឹកស្មានទេ ហើយមិននឹកស្មានថាគេក្មេងគេមកយកយើងចាស់អញ្ចឹងដែរ!!

ក៖ ចាំ!!

ខ៖ ហើយយើងមេម៉ាយដល់កូន៣។

ក៖ ហើយគាត់ម៉េចទៅមីង?

ខ៖ ហើយក៏ចាប់ដៃគ្នាតាំងពីឆ្នាំ២០០០មក។

ក៖ ២០០០?

ខ៖ ចាំតាំងពីឆ្នាំ២០០០មក!!

ក៖ហ្ហូយូរណាស់ដែរហើយហ្នឹងអីចឹង?

ខ៖ ហ្នឹងហើយតាំងពីឆ្នាំ២០០០ បើនិយាយទៅញ៉ុមរៀបជាមួយគាត់ថ្ងៃ១៨ ខែ០៣ ឆ្នាំ២០០០គត់។

ក៖ ចាំយូរណាស់ហើយហ្នឹងអីចឹង!!

ខ៖ ចាំ!!

ក៖ តែពូមើលទៅស្រលាញ់មីងស្មោះណាស់!!

ខ៖ បើគិតទៅ១៨ឆ្នាំពេញហាំ!!

ក៖ ចាំ!!ហើយកូនអាអូន(អាយុ)ប៉ុន្មានហើយ?
ខ៖ អាអូនហ្នឹងកើតឆ្នាំ២០០៤!!
ក៖ ហ្ហ៎អញ្ចឹងបានប៉ុន្មាន?
ខ៖ ១៤ ១៥ឆ្នាំហើយ!!
ក៖ ចាំអញ្ចឹង មីងម៉េចដែរ រស់នៅជាមួយគ្នាសព្វថ្ងៃសុខទុក្ខម៉េចដែរ ធម្មតាអញ្ចឹងទៅមីងហោ?
ខ៖ ធម្មតាអត់ដែលមានបញ្ហាអីផង!!សុខទុក្ខចេះតែទៅជាមួយគ្នាអញ្ចឹងទៅ។
ក៖ ចាំ ហោងហើយមីងបានប្តីក្រោយសមប្រកបអីចឹង មិនដូចពូពេលមុនកំពូល!!!
ខ៖ ចាំ គ្រាន់ថាមកមួយនេះខ្ញុំសមប្រកបដូចថាមិនដែលចេះរករឿងមិនដែរចេះមាត់ករធំតូចដាក់ខ្ញុំដាក់កូនចៅអត់សុទ្ធគិតទៅគាត់មកគ្រប់គ្រងកូនហាំ!!ដូចកូនគាត់បង្កើតសាច់គាត់បង្កើតអីចឹង!!
ក៖ ចាំ!!
ខ៖ គាត់មិនដែលមានកូនមានចៅទេ!!
ក៖ ចាំ!!
ខ៖ មិនដែលកូនញ៉ុមណាមិនដែលជេរកូនមួយម៉ាត់វ៉ៃកូនមួយដៃអីអត់រលីង!!
ក៖ មែនហ្នឹងឃើញពូស្លូតមែនហ្នឹង!!
ខ៖ អត់សោះ !!
ក៖ សមតែមើលទៅថាពូស្វារ!!
ខ៖ ហ្នឹងហើយ!!
ក៖ តែអត់ផង!! អ្នកមីងអ្នកមីងតាមពិតអ្នកមីងស្កូវតាំងពីយូរនៅ?
ខ៖ ញ៉ុមស្កូវតាំងពីក្មេង!!
ក៖ ម៉េចបានទៅអីចឹងជំងឺអីគេទៅអ្នកមីងបានអីចឹងវិញ?
ខ៖ បើនិយាយទៅ និយាយទៅគេថាស្កូវរោគហាំ!!
ក៖ ហ្ហ៎មីងឈឺអីគេវិញ?
ខ៖ អើយបើតាមគេថានេះទៅគេថាស្កូវរោគ ស្កូវឬសដូង!!
ក៖ ហ្ហ៎ មកពីអញ្ចឹងទេមីងណេះ?
ខ៖ ចាំ!!
ក៖ អាយុប៉ុន្មានចាប់ផ្តើមសក់សរអ្នកមីង?
ខ៖ ញ៉ុមសក់ស្កូវកាលពីក្មេងអាយុ១២ឆ្នាំ អត់ដែលដល់តែពេលយើងចាប់ស្កូវខ្លាំងយើងហ្នឹងអាពេលអាយុ៤០ជាង!!

ក៖ ហ្ហ៎!!
ខ៖ អាហ្នឹងសរមែនទែនម៉ង!!
ក៖ អញ្ចឹងកាលការជាមួយពូមុនក៏សក់សរខ្លះៗហើយមីងណោះ?
ខ៖ ចា៎!!សក់ស្កូវខ្លះហើយ!!
ក៖ ចា៎!!តែ!
ខ៖ កាលពីញ៉ុមជួបគាត់ញ៉ុមអាយុ៣៣!!
ក៖ ចា៎!!
ខ៖ ៣៣ ៣៤ គាត់អាយុ២០ហ្នឹង!!
ក៖ ចា៎ហ្នឹងហើយ តែមានអីផង!! ពេលខ្លះមុខជំលៀសៗគ្នាដោយសារមីងតាមពិតមុខនៅក្មេងទេ តែដល់ពេលដោយសារសក់សរអីចឹងទៅរៀងវាចាប់ផ្តើមកើនអាយុតិចណាស់!!តាមពិតពេលពិនិត្យមែនទែនមីងអត់ទាន់ចាស់ទេណាស់!!
ខ៖ ញ៉ុមអត់ទាន់ចាស់ទេ!!
ក៖ មែនញ៉ុមនិយាយត្រង់មែន មិនមែននិយាយថាបង្អប់អីទេ មិនមែននិយាយថាភររបៀបថាបញ្ជោរអីវ៉ាន់ដែរ តែវាការពិតមែន មីងលៀបសក់ខ្មៅអោយគ្រឹបមើល៤០ជាងឥលូវហ្នឹង!!
ខ៖ លាបខ្មៅមានកើតណា។
ក៖ ម៉េចអញ្ចឹងមីង?
ខ៖ លាបខ្មៅទៅវាចេញមកសរស្កោះពេកម៉ងហា៎!!
ក៖ អីចឹងដល់តែលាបពណ៌មីងហេ?
ខ៖ ចា៎ លាបពណ៌ចេះតែបន្តិចៗតែបើថាលាបខ្មៅចេញមកសរតែម្តង!!
ក៖ ចុះបើកក់វិញមីង?
ខ៖ កក់អត់កើត!!
ក ៖ កក់ខ្មៅហ្ហ៎!!!
ខ៖ កក់ក៏អត់កើតដែរ !!!!
ក៖ ហ្ហ៎!!
ខ៖ សាកអស់ហើយ។
ក ៖ហ្ហ៎អញ្ចឹងហេ?
ខ៖ សាកអស់រលីងហើយ អត់ចង់លាបពណ៌សោះហើយ!!

កៈ ហ្នឹងហើយ។
ខៈ ប៉ុន្តែដល់ពេលដាក់ទៅបានមួយអាទិត្យអីកន្លះខែចេញមកសរស្តោះតែម្តង!!
កៈ ចា៎!!
ខៈ វាសរពេញហ្នឹងទាំងអស់ម៉ងហា៎ វាអាក្រក់មើលទៀត!!
កៈ តែអត់អីទេ !!
ខៈ ដាក់អញ្ចឹងទៅវាបន្លំៗ!!
កៈ
ហ្នឹងហើយញុំមគិតថាដាក់អញ្ចឹងទៅវាមិនអីទេ!!ចា៎អត់បញ្ហាដោយសារមួយហ្នឹងជាជំងឺដែលយើងទប់មិនបានមីងហា៎!!
ខៈ ចា៎!!
កៈ តែសុខភាពឥឡូវល្អធម្មតាតើអ្នកមីងហេ?
ខៈ សុខភាពញុំមត្រឹមញុំមអាត្រឹមម៉ូតូបុកមកវាទ្រុឌទ្រោមមែនទែនតែម្តង!!
កៈ ប៉ុន្មានឆ្នាំហើយ?ហ្នឹងហើយញុំមឮមួយហ្នឹងដែរ!!
ខៈ ម៉ូតូបុកហ្នឹងបើគិតទៅវាអត់ទាន់បាន៥ ៦ខែផងហ្នឹង!!ពីខែ១១។
កៈ ទឹមតែឥឡូវៗហ្នឹងដែរទេហេ?ហើយម៉េចគ្រោះថ្នាក់ធំទេមីងពេលហ្នឹង?
ខៈ ពូឌុបទៅផ្សារទៅទិញគ្រឿងបបរលក់កាលហ្នឹងអត់ទាន់ចូលធ្វើការហ្នំ!!
កៈ ចា៎!!ហើយធ្វើហើយតែរោងចក្រគេផ្អាក គេផ្អាកវិញហ្នំ!!ហ្នឹងហើយឮមួយហ្នឹងដែរ!!
ខៈ ហ្នឹងហើយដល់ពេលចាប់ផ្អាកវិញគាត់ថាអញ្ចេកយើងអត់មានអីទេថាយើងជំពាក់លុយជំពាក់កាក់គេអីចឹងគេមិនរងចាំយើងពេលបើកលុយបើកអី!!
កៈ ហ៊ឺ!!
ខៈ ឥឡូវបងអើយ ឥឡូវបងអត់មានការងារធ្វើអញ្ចឹងយើងលក់ដូរគ្រាន់តែចិញ្ចឹមជីវិតសិនទៅជំពាក់គេចេះតែសងតិចតួចអីចឹងទៅណាស់ ទៅទិញថ្មើរហ្នឹងអីចឹងហ៊ា!!ទៅទិញត្រីបបរជិះអញ្ចឹងហ៊ាអាម៉ូតូមកពីណាមកវាបុកឯងពីក្រោយមុំាងទៅវាទៅហួសបណ្តោយទៅ!!
កៈ ហ៊ឺអត់ឈប់មើលទៀត!!
ខៈ ម៉ូតូពួកអាអង្គការ ពួកអាអង្គការដើរយកលុយគេហ្នឹង!!
កៈ អើយ!!
ខៈ
ចា៎អត់មានសួរយើងអីមួយម៉ាត់ញុំមអុកគូទញាច់នៅនឹងថ្នល់ហ្នឹងបាត់មាត់បានករទៅពូក៏ទៅដួលដោយខ្លួនទៅ!!

កៈ  ទល់ហើយមីងហោ?
ខៈ  ចាំញុំម!!ឥឡូវហ្នឹងចុកណៃនអួលពេញម៉ង ឡើងកោងហើយហ្នឹង កោងអញ្ចេក!!
កៈ  ហើយមិនទៅពេទ្យទៅអី?
ខៈ  ទៅ!!ហើយទទួលវាជិតការកូនទៀត!! ការកូនថ្ងៃទី១១ខែ១៧ហើយយើងបុកខែ១១ហ្នឹងទៀត។
កៈ ចំ!!
ខៈ  ម្ល៉ោះហើយចេះតែប្រឹង ចាក់ថ្នាំផងផឹកផងហើយយើងថ្នាំសរសៃចេះតែប្រឹងហ្វាំ!!
កៈ ចាំ!!
ខៈ ដល់ឥឡូវវាចាប់ផ្ដើមធ្វើទុក្ខ!!
កៈ ចាំចុះឥឡូវ ចេះតែតាមដានទៅអ្នកមីងអើយ!!
ខៈ  ចាំឥឡូវនៅឈឺពេញខ្លួនពេញប្រាណទាំងអស់!!
កៈ មានរងពន្លៃរឹតអី?
ខៈ  រឹតអស់ហើយពន្ទេឡូតែមិនដឹងជាយ៉ាងម៉េច!!
កៈ ដល់តែទៅពិនិត្យ!!
ខៈ ចាំ!!
កៈ ឆ្អឹងថតមើលបានកើត!!
ខៈ  ហ្នឹងហើយ!!
កៈ  អញ្ចឹងមីងចូលដល់កន្លែងចំនុចមួយទៀត កន្លែងដែលពីនេះហាំសង្គ្រាមអ្នកមីងកើតទាន់សង្គ្រាមមែនទេ?
ខៈ ចាំ!!
កៈ  មីងឥឡូវនិយាយពីជំនាន់លន់  នល់សិនមើលមុនជំនាន់ប៉ុល ពតតើជីវិតអ្នកមីងជួបរឿងអីគេខ្លះពេលលន់នល់ហាំ?
ខៈ  កាលពីជំនាន់លន់  នល់ហ្នឹងខ្ញុំហ្នឹងវានៅតូចដែរទេ  ញ៉ុមទឹមតែ៨ឆ្នាំទេ តែគ្រាន់តែថាអង្កាលពេលជំនាន់លន់  នល់ហ្នឹង កាលពីមុនញ៉ុមទៅនៅភ្នំពេញហ្នឹងខ្ញុំនៅស្រុកហ្នឹង ដល់តែគេបានផ្លោងចូលអីហ្នឹងប៉ាញ៉ុមហ្នឹងនាំម្ដាយញ៉ុមនាំយាយញ៉ុមហ្នឹងទៅនៅស្អាតចាស់ពីសង្គមហ្នឹងហាំ!!
កៈ ចាំ ចូលទៅភ្នំពេញវិញ!!

ខ៖ ចាំចូលទៅភ្នំពេញចូលទៅស្អាតចាស់ នៅស្អារចាស់ហ្នឹងនៅហ្នឹងក៏មានបញ្ហាអីគេដែរ នៅបានសុខសប្បាយទេ ដល់ពេលយើងចូលឆ្នាំ៧៥(១៩៧៥)!!

ក៖ មីងនៅក្នុងហ្នឹងអត់ធ្លាប់ឮគ្រាប់ផ្លោងឮគ្រាប់អីទេមីងហេ?

ខ៖ មាន!!

ក៖ ម៉េចដែរឮផ្លោងនៅភ្នំពេញដែរ?

ខ៖ អើយឮផ្លោងនៅភ្នំពេញអញ្ចឹងទៅមក ព្រោះអីជួនកាលញ៉ុមឈរមើលគ្រាប់ផ្លោងទៀត ចុះកប៉ាល់ហោះទំលាក់ហ្នំ!!

ក៖ ចាំ!!

ខ៖ មិនមានភ្លើងគេរ៉ឺតៗចុះមក!!

ក៖ អូ!

ខ៖ នាំគ្នាយាយញ៉ុមហ្នឹងនាំគ្នារត់ទៅក្រាបនៅត្រង់សេត្រង់អីអញ្ចឹងទៅណាស់!!

ក៖ ចាំខ្លាចមកដល់នេះមកដល់អញ្ចឹងទៅហេ?

ខ៖ ចាំគ្រាន់តែពេលហ្នឹងយើងនៅក្មេង យើងចេះតែនិយាយលេងជាមួយជីដូនពន្ទាក់គាត់អីអញ្ចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ ពេលគ្រាប់ផ្លោងអាពេលទំលាក់គ្រាប់មកមិនរ៉ឺតៗញាំងៗៗៗៗៗរាវៗៗៗៗៗៗហ្នឹងមកមកមិនខ្លាំង!!

ក៖ ចាំ!!

ខ៖ ចូលចិត្តធ្វើសំលេងអ៊ីចឹងបន្លាចជីដូនលេងទៅណាស់!!

ក៖ ហើយគាត់ខ្លាចដែរ?

ខ៖ បន្លាចលេងមកចូលត្រង់សេៗអញ្ចឹងទៅណាស់!!ដល់ហើយគាត់ថាតោះមកថៅតោះទៅ អញ្ចឹងទៅណាស់!!ហើយយើងកាលហ្នឹងដូចថាយើងលេងសើចជាមួយយាយទៅណាស់ យើងនៅក្មេងមានទៅដឹងអី!!!

ក៖ ចាំ!!

ខ៖ អញ្ចឹងទៅហើយផ្លោងគ្រាប់ផ្លោងមកវាទំលាក់យប់ជួនកាលយប់ជួនកាលថ្ងៃអញ្ចឹងទៅ។

ក៖ តែអត់មានត្រូវនៅភ្នំពេញទេមីងហេ?

ខ៖ អត់មានទេ អត់មានទេ!!

ក៖
មួយៗអ្នកនៅតាមចំការអីអញ្ចឹងអីវ៉ាន់ភាគច្រើនគឺឃើញច្រើនណាស់តែដល់ពេលញ៉ុមឮម៉ែញ៉ុមនិយាយដែរថាដល់ពេលទៅភ្នំពេញទៅអីអញ្ចឹទៅធូរមីងណាស់
គេមិនទំលាក់នៅក្រុងទេ!!ខ៖ ចាំ!!អត់ទេ។
ក៖ វាទំលាក់មិនមែនចង់សម្លាប់ប្រជាជនទេ គេសម្លាប់អាពួកពួកអាទ័ពអាពួកស្អីគេខ្មែរក្រហមហ្នឹង!!
ខ៖ ខ្មែរក្រហម!!
ក៖ ដោយសារអត់ត្រូវគ្នា។
ខ៖ ខ្មែរក្រហម ខ្មែរខៀវអីហ្នឹង ខ្មែរក្រហមខ្មែរខៀវអីហ្នឹងអាពតអីហ្នឹង!!
ក៖ ហ្នឹងហើយ ញ៉ុមឆ្ងល់ថាម៉េចបានកើតទៅជាក្រែងមុនដំបូងឃើញស្រលាញ់ដោយសារខ្មែរក្រហមហ្នឹងរំដោះកាន់ជើងខាងស្តេច
ហើយអីចឹងយូរៗម៉េចកើតគំនិតសម្លាប់គ្នាឯងវិញទៅហាំ!!
ខ៖ ពិបាកដែរ!!ក្បត់តគ្នាអាហ្នឹងអីចឹង!!
ក៖ហ្នឹងហើយ ហើយដល់ពេលទៅកើតគំនិតមកសម្លាប់បងប្អូនឯង!!
ខ៖ ហ្នឹងហើយ!!
ក៖ សម្លាប់ប្រជាជនឯងឡើងរង្គាលឡើងសាហាវ ម៉េចទេ ឥឡូវមីងនិយាយពេលចូលដល់មកប៉ុល ពតវិញមើល ថ្ងៃដំបូងចូលជំនាន់ប៉ុល ពតមីងមានជួបរឿងអីគេខ្លះ?បានដឹងថាបានធ្លាក់ចូលទៅក្នុងជំនាន់ប៉ុល
ពតបានហូបបាយរួមបាយអីជាមួយគ្នាអញ្ចឹងហាំ??ម៉េចវិញទៅមីង?
ខ៖ ញ៉ុមកាលហ្នឹងអាពតវាឡើងដេញចេញមកពីភ្នំពេញមកហ្នឹងជាមួយម៉ែញ៉ុមជាមួយប៉ាញ៉ុមហ្នឹងដេញមកអញ្ចឹងដេញចេញមកទាំងយប់ហ្នឹង
ញ៉ុមហើមដើញលឺបហើយញ៉ុមប៉ាញ៉ុមលើកញ៉ុមដាក់លើម៉ូតូម៉ូម៉ាលែនហើយអង្ករមួយបាវហ្នឹងមក!!!!
ក ៖ចាំ!!
ខ៖ អង្ករមួយបាវពីសង្គមអាអង្ករអាឆ្នុតខៀវហាំ!!
ក៖ ចាំ!!
ខ៖ បណ្តើរចុះមកចុះមកតាមផ្លូវជួបខ្មោចគ្រប់កន្លែង!!
ក៖ ហ៊ឺ!!
ខ៖ ខ្មោចជូនកាលឡានកិនតាប៉ែតអីចឹងទៅ!!

កៈ ចំ!!
ខៈ ជូនកាលវានៅដេកស្តូកអញ្ចឹងទៅ ចងមុងដេកជាមួយខ្មោចអត់ដឹងហាំ!!
កៈ ហើយចុះមានឃើញពោះវៀនប៉ាតាំងអស់ហើយអញ្ចឹងមីង?
ខៈ ចាំអញ្ចឹងទៅ ខ្មោចដេកស្តូកៗតាមផ្លូវអញ្ចឹងរហូតហ្នឹង!!
កៈ អាហ្នឹងពេលទឹមតែចូលបន្តិចៗមកអញ្ចឹងហោ?
ខៈ យើងចុះមកពីភ្នំពេញហ្នឹង។
កៈ ហ៊ឹៗ!
ខៈ ដូចថាគេបាញ់សម្លាប់អីចឹងទៅគេគៀរប្រជាជនចុះមកអញ្ចឹងទៅ គេដេញចុះមកជូនកាលចាស់ជរាយកមកអត់កើតអញ្ចឹងចោលខ្មោចតាមផ្លូវស្លាប់តាមផ្លូវអីអញ្ចឹងទៅ!!ជូនខ្លះមានអ្នកត្រូវគ្រាប់អីអញ្ចឹងទៅ ខ្លះអ្នកជំងឺយកម្តាយអីចេញមកពីពេទ្យមកអញ្ចឹងទៅណាស់ដាច់ខ្យល់អីហ្នឹងស្លាប់អាដូកអាដូកអីអញ្ចឹងទៅ
ប៉ុន្តែគ្រាន់តែថាអ្នកស្លាប់ដោយសារជំងឺវាភាគតិច។
កៈ អញ្ចឹងមីងនៅក្នុងមន្ទីរពេទ្យសាលារៀនអីវ៉ាន់ដេញចេញមកទាំងអស់ម៉ងមីងហោ?
ខៈ ដេញចេញមកទាំងអស់ អត់មានសល់ទេ!!
កៈ អូយ!!មីងអើយមីង!!ហើយញ៉ុមចុះដំនើរមកហ្នឹង ញ៉ុមចុះដំនើរមកហ្នឹងងាប់តាមផ្លូវហ្នឹងច្រើនណាស់ ដេកតាមផ្លូវហ្នឹង ជូនកាលចងមុងដេកអញ្ចឹងទៅ ព្រលឹមឡើងបានឃើញខ្មោចនៅក្បែរមុងអីអញ្ចឹងទៅ។
កៈ ហ៊ឺ!!!!!
ខៈ ចុះយើងយប់ហ្នំ!!
កៈ អត់ដឹង!!
ខៈ ចាំយប់អត់ដឹងដេកចេះតែចងទៅចងអោយកូនចៅអោយចេះតែបានដេកទៅណាស់ យើងចុះមកហ្នំ!!ជូនកាលដាក់ដាំបាយក្បែរហ្នឹងទៅជូនកាលគ្រាប់បែកផ្ទុះក្បែរហ្នឹងទៅ វាក្តៅហ្នំ តែវាចេះតែសុខសប្បាយដែរ យើងដាំបាយដាំអីយើងមើលអត់ឃើញ យើងមើលឃើញខែវាងងឹត ចុះមានភ្លើងមានអីមកពីណាគេផ្តាច់ភ្លើងផ្តាច់អីអស់ហើយហ្នឹង។
កៈ ហ្នឹងហើយ!!
ខៈ ហើយដល់ដាំបាយអញ្ចឹងទៅជូនកាលជីកចង្រ្កានកល់ដាំបាយអញ្ចឹងទៅក្បែរគ្រាប់បែកគ្រាប់អីអញ្ចឹងទៅ!!!
កៈ ពេញដីម៉ងពេលមុនមីងហោ?

ខ៖ ចាំកាលហ្នឹងវាពេញមែន កាលហ្នឹងខ្មោចងាប់ថាឡើងម៉ាអាដូកម៉ងហ្នឹងហាំ!!តាផ្លូវហ្នឹងហា!!ចុះមក។

ក៖ អូយមីងអើយគិតពីទិដ្ឋភាពហ្នឹងហាម៉េចទៅមីង!!សូម្បីតែមកសម័យឥឡូវហ្នឹងនេះឃើញពេលមនុស្សស្លាប់ហ្នឹងទៅមើលអត់ចង់ហ៊ានទៅមើលផង។

ខ៖ ហ្នឹងហើយ។

ក៖ គ្រាន់តែគ្នានៅរូបរាងស្អាតតែគ្រាន់តែអត់ដង្ហើមអីចឹងទៅណាស់!!

ខ៖ ចាំ!!

ក៖ ឃើញស្លេកឃើញអីខុសពីយើងនៅរស់!!

ខ៖ ចាំហ្នឹងហើយ!!

ក៖ នៅរស់មានព្រលឹងមានវិញ្ញាណអីហ្នឹងអញ្ចឹងហាំ!!ហើយដល់ពេលអ្នកមីងទៅឃើញអាណ្ហកអាណែលពេញផ្លូវទៀតមីងអើយ!!

ខ៖ អាណ្ហកអាណែលពេញផ្លូវ ឃើញអស់ហើយ ឃើញមកតាមផ្លូវ!!

ក៖ ហ្នឹងហើយ!!

ខ៖ សង្គ្រាមហ្នឹងនៅជំនាន់សង្គ្រាមហ្នឹង!!នឹកឃើញជំនាន់ហ្នឹងច្បាស់ជាងគេ!!ឃើញចុះមកពីភ្នំពេញអាហ្នឹងឃើញស្លាប់ហើយអាហ្នឹងជាក់ស្តែងភ្នែកម៉ងហាំ!!

ក៖ ចាំ!!មួយនេះមិនមែនរឿងទេណាស់មីងហាំ!!ការពិតហាំ!!

ខ៖ ការពិត!!

ក៖ អ្នកដែលរួចផុតពីជំនាន់ហ្នឹងសំណាងខ្លាំងណាស់មីងអើយ!!!

ខ៖ តែញ៉ុមថាអ្នកដែលសល់ពីជំនាន់ហ្នឹងគ្រាន់បើជាងជំនាន់ប៉ុល ពត!!

ក៖ សល់ពីជំនាន់លន់ នល់ហេ?

ខ៖ ចាំ!!

ក៖ ហ្នឹងហើយ ដល់ពេលជំនាន់ប៉ុល ពតម៉េចទៅមីង?

ខ៖ មកពីជំនាន់ប៉ុល ពតហ្នឹងញ៉ុមថាបានថ្លៃជាងអ្នកអ្នកសល់អ្នកនោះ!!

ក៖ អ្នកសល់ពីជំនាន់លន់ នល់!!

ខ៖ អ្នកសល់ពីជំនាន់ប៉ុល ពត បានអាយុថ្លៃជាង!!

កៈ និយាយទៅអត់ឃើញមានសង្គ្រាមណាដូចសង្គ្រាមជំនាន់ប៉ុលពតទេមីង!!មើលមីងនិយាយពីជីវិតមីងនៅក្នុងជំនាន់សង្គ្រាមហ្នឹងមើល?
ខៈ សង្គ្រាមប៉ុល ពតហ្នឹងញ៉ុមអត់មាននៅនេះទេ ញ៉ុមគេយកទៅអង្គភាពយកទៅដាក់នៅអង្គភាពដោយខ្លួន គេយកបំបែកពីឪពុកម្តាយចេញពីមកអង្គភាពដោយខ្លួនទៅទូលអាចមន៍គោអញ្ចឹងទៅ ជូនកាលគេអោយទៅជីកប្រលាយ នេះប្រលាយអាគគីរជ្រុំយើងហ្នឹងអាជីកតាមហ្នឹងពួកញ៉ុមទូលសុទ្ធតែបង្គីដែកហ្នូ!!ហ្នឹង!!
កៈ បង្គីដែក!!
ខៈ អាបង្គីដែកធំៗអញ្ចេក!!
កៈ តែឥឡូវលែងមានហើយមីងហេបង្គីដែកហ្នឹង?
ខៈ ចាំ!!ឥឡូវលែង ឥឡូវដូចអត់ដែលឃើញទេ!!
កៈ មិនដឹងគេបង្កើតយកមកពីស្រុកណាវិញទេ?
ខៈ មិនដឹងយកមកពីណាទេ!!
កៈ មានតែយកមកពីវៀតណាមហើយចិនអីវ៉ាន់ហ្នឹង!!
ខៈ ប៉ុន្តែគ្រាន់តែថា!!វាបើនិយាយទៅពីអាពតវាសាហាវឃោរឃៅណាស់ ញ៉ុមព្រាត់ប្រាស់ម៉ែឪតែទាំងអស់ហ្នឹង!!!គេចាប់ញ៉ុម គេចាប់ញ៉ុមចងសេកប្រុងយកញ៉ុមទៅសម្លាប់ចោលប៉ុន្មានដងហើយ!!!
កៈ ចំ!!
ខៈ តែយើងរលឹកឪពុកម្តាយមិនទៅរក ទៅរកអីចឹងគេចាប់ចងសេកឈរហាលក្តៅ ឈរអញ្ចឹងទៅ គេចាប់ញ៉ុមចងដាក់ជាមួយសរសរអញ្ចឹងហិដាក់បាយមុខអោយយើងស៊ី យើងសួរថាយើងស៊ីកើតដែរ?បើគេចងយើងជាប់សរសរហ្នឹងដាក់បាយនៅមុខអោយយើងអោនហូប យើងហូបម៉េចកើត ហូបមិនកើតទេ!!
កៈ មើលតែសត្វធាតុអីហើយណោះមីង វាធ្វើអញ្ចឹងហា!!!
ខៈ ចាំ!!
កៈ ហេពួកអានេះ!!
ខៈ ញ៉ុមរាអាពតញ៉ុមព្រាត់ម៉ែព្រាត់ឪរហូតទឹមតែមកបែកអាពតហ្នឹងមកបានបានជួបគ្នាហ្នឹង។កៈ ចាំ!!

ខ៖ ជួបគ្នាហ្នឹងដោយសារអញ្ចេះទេ ខ្ញុំកំពុងគេអោយធ្វើស្មីកំពុងតែដកសំណាប់ឬមួយក៏អីទេហ្ន៎កំពុងតែប្រលេះពោត គេអោយប្រលេះពោតនោះ!!!ស្រាប់ហើយកងទ័ពហ្នឹងមកកងទព័ហ្នឹងមកគេថាក្មេងៗទៅរកម៉ែឪទៅ គេថាអញ្ចឹង។

ក៖ ចា៎!!

ខ៖ ទៅរកម៉ែឪទៅព្រោះអីពួកយួនចូលពេញអស់ហើយ ពួកញ៉ុមហ្នឹងគេថាគេរំសាយអង្គភាពអីណាណី គេរំសាយអីអត់ហើយក្មួយៗទៅរកផ្ទះរកសម្បែងទៅរកម៉ែរកឪទៅ ញ៉ុមណេះចេញមកទៅមានតែខោមួយចង្កេះចេញមកមក ខោអាវនៅកន្លែងក៏អត់មានយកមកដែរក៏រត់ទៅ រត់ទៅកោះខ្សាច់ជន្លាទៅកន្លែងម្ដាយញ៉ុមហ្នឹង!!!

ក៖ តែដឹងកន្លែងហើយមីងណេះ?

ខ៖ ដឹង ដល់តែពេលទៅបងញ៉ុមនៅទួលក្រសាំងណេះ ម៉ែញ៉ុមនៅដេកពេទ្យ ដេកពេទ្យនៅកោះខ្សាច់ជន្លាហ្នឹងហា!!

ក៖ ចា៎!!

ខ៖ ញ៉ុមរត់ទៅរកតែម៉ែញ៉ុមទេ ឆ្លងទៅកោះហ្នឹងអត់មានទូកទៀតហើយជីដូនញ៉ុមហើយប្អូនញ៉ុមនៅកោះហ្នឹងទាំងអស់។

ក៖ នៅកោះខ្សាច់ជន្លាហ្នឹងហេ?

ខ៖ ចា៎នៅកោះខ្សាច់ជន្លាហ្នឹង ទំរាំតែបាននឹងឆ្លងទៅ ឆ្លងទៅជួបយាយជួបប្អូនណោះហើយដល់តែពេលមកវិញម្ដាយញ៉ុមហើមភ្នែកឡើងប៉ុនៗករដៃ!!

ក៖ ហ៊ឺ!!

ខ៖ ហើមភ្នែកដើររាវមកអញ្ចឹងហើយញ៉ុមដឹកដៃម្ដាយផងទូលបង្វិចផង ហើយអើរដឹកដៃយាយផងយាយកោងហ្ន៎!!យាយគាត់កោងខ្នងហា៎!!

ក៖ ហ៊ឺៗ!!

ខ៖ ហើយប្អូនញ៉ុមអាពៅមីពៅហ្នឹង ហើយអាមួយនៅស្រែអំបិលហ្នឹងមកឆ្លងមកអត់មានទូកឆ្លងទេ ម្ដាយញ៉ុមហា៎គាត់សល់ដែកកេះមួយ អោយដែកកេះក្មេងមួយអោយចំលងហា៎!!អោយចំលងមកត្រើយខាងណេះឆ្លងពីកោះមកហា៎!!

កៈ ចាំ!!

ខៈ ឆ្លងមកត្រើយខាងណោះបានដើរពីណោះមកដល់ស្រុកហ្នឹងហិ!!ដើរឈប់ ដើរឈប់ដើរឈប់ ព្រោះអីយាយកោង ម្ដាយភ្នែកឈឺទាំងសងខាងទាំងអស់។

កៈ តែមីងម្នាក់ឯងរ៉ាប់រង?

ខៈ ដើរមក មិនមែនញ៉ុមអ្នករ៉ាប់រងទេថាដើរមកថាចេះតែបណ្ដើរមកអញ្ចឹងទៅណាស់!!!កៈហ្ហ៎!!ខៈ

ញ៉ុមទូលបង្វិចអីចឹងទៅ!!ទូលអីចឹងទៅដាក់នៅមុខអីចឹងទៅទុកហ្នឹងម៉ុំអីចឹងទៅញ៉ុមទៅជួយយកយាយអីចឹងហាំ

យាយដើរមកអញ្ចឹងទៅហាំម៉ែឯងអង្គុយហ្នឹងទៅកុំអោយហាត់យើងចេះតែបណ្ដាក់ៗទៅមុខទៅណាស់!!

កៈ ហ៊ឺ!!

ខៈ ចុះបើម្ដាយគាត់ឈឺភ្នែកឡើងហើមសងខាងឡើងប៉ុនៗណាណើហើយហ្នឹង។

កៈ គាត់មើលឃើញទេ?

ខៈ គាត់មើលឃើញគ្រាន់តែហើមភ្នែក!!

កៈ ព្រាលៗ!!

ខៈ ហើមដូចអារបៀបថាអាឈឺភ្នែកក្រហមហាំ!!

កៈ ចាំ!!

ខៈ ហើមឡើងប៉ុនៗករដៃម៉ង!!

កៈ អូយ!!

ខៈ ហើយដល់ពេលញ៉ុមណោះហើយដល់ពេលណាមួយយាយកោងអីចឹងហិដើរឈើច្រត់កាន់កោងៗៗមកអីចឹងទៅគាត់ហាត់គាត់ គាត់ជរានោះ!!

កៈ ហ៊ឺ!!!

ខៈ អីចឹងទៅយកគាត់មកដាក់នៅត្រឹមហ្នឹងអីចឹងទៅញ៉ុមទៅទូលអាបង្វិចហ្នឹងទៅចន្លោះប្រហែលជា១០ម៉ែត្រអីចឹងទៅឈប់ម្ដងអីចឹងទៅមកជួយយកអីចឹងទៅវិញអីចឹងទៅណាស់។

កៈ ចាំ!!

ខៈ អីចឹងទៅ!!

កៈ
ហ៊ីៗ!!មីងអើយញ៉ុមគ្រាន់តែនឹកឃើញពេលហ្នឹងហារបៀបថាមីងនិយាយមកស្រម៉ៃមើលពេលហ្នឹងថាម៉ែក៏ឈឺ ជីដូនក៏ចាស់ជរា!!
ខៈ ជរា!!
កៈ ហើយឪពុកត្រូវគេសម្លាប់!!
ខៈ ហ្នឹងហើយគេសម្លាប់ចោល!!
កៈ
បងប្អូនមិនដឹងនៅណានៅណី!!ហើយប្រទេសជាតិឡើងរីកវរអារម្មណ៍ពេលហ្នឹងមិនដឹងវេទនាខ្លាំងប៉ុណ្ណាទេមីងអើយ!!
ខៈ បងញ៉ុមនៅទួលក្រសាំងណោះបែកគ្នា!!
កៈ ហ៊ីៗ!!
ខៈ បងប្រុសញ៉ុម។
កៈ មីងអាពេលមីងប្រាប់ញ៉ុមថាចងសេកនោះហ្ន៎ ពេលហ្នឹងម៉េចបានវាស្រាយមីងមកវិញ?
ខៈ អើយមើលវាចងយើងមួយថ្ងៃ វាគេហៅយើងថាសេរី!!
កៈ សេរីដើរទៅរកម៉ែរកអីអញ្ចឹងទៅណោះ?
ខៈ ហ្នឹងហើយសេរី សេរីយើងអត់ទៅធ្វើការទេយើងរត់ចោលអង្គភាពអីអញ្ចឹងទៅណាស់!!
កៈ ហ៊ីៗ!!
ខៈ គេចងយើងឡើងមួយថ្ងៃវាស់ល្ងាច អត់អោយបាយយើងស៊ីទេអោយបាយយើងស៊ីតែដៃយើងជាប់ចំណងយើងហូបម៉េចកើត!
កៈ ហ៊ីៗ!!
ខៈ ដល់តែពេលដល់ម៉ោងជិត៩បានវាស្រាយ !!
កៈ ហ៊ីៗ!!ហើយបានហូបបាយនៅហ្នឹងវិញទៅ?
ខៈ
ស្រាយដល់ហើយវាអោយបាយអោយអីស៊ីអញ្ចឹងទៅដល់ហើយបានទៅដល់កន្លែងដេកវិញទៅដៃហ្នឹងហើមអីអស់ហើយ!!
កៈ ចាំចងរឹត!!
ខៈ ស្លាក់ខ្យល់ហ្ន៎!!
កៈ ហ៊ីៗ!!
ខៈ ស្លាក់ខ្យល់ហ្នឹង!!

កៈ ចងឡើងរឹតម៉ងមីងណោះ?

ខៈ  ចាំ!!ចុះវាចងយើងដែលចងបន្ទូរ!!

កៈ ហ៊ឺ!!!

ខៈ ម៉េចគេហៅថាធ្វើទារុណកម្មហ្នំ!!

កៈ ហ្នឹងហើយម៉េចតែចម្មតាយើងចងដៃយើងឡើងស្លេកហើយហ្នឹង!!

ខៈ  ហ្នឹងហើយ។

កៈ ចុះទំរាំតែមីងមួយថ្ងៃវាស់ល្ងាចទៀត!!

ខៈ  មួយថ្ងៃវាស់ល្ងាចចងយើងយើងឈរអឺចឹងទៅ!!

កៈ ហ៊ឺ!!

ខៈ
ហ្នឹងសំណាងដែលវាអោយឈរហោលក្តៅហាំតែបើវាដាក់យើងនៅក្នុងសំបុកអង្រងសំបុកស្រមោចទៀត ក្តៅផងសំបុកស្រមោចសំបុកអង្រ្កងទៀត!!

កៈ ងាប់បណ្តោយ ងាប់ហើយមីងឮឃើញអាទិដ្ឋភាពអញ្ចឹង !! មានអាខ្លះមានអញ្ចឹងទៀតមីងហោ?

ខៈ មានតើ!!

កៈ  សាហាវណាស់ពួកអាអស់នេះ!!

ខៈ មានតើ!!

កៈ តាមពិតហាំកុំគិតថាធ្វើអញ្ចឹងហើយហ្អែងរួចខ្លួនអោយសោះទោះតែមិនឥឡូវនៅលើផែនដីគ្មានអាណាគេធ្វើបាបហាំតែចុងក្រោយនឹងសងមនុស្សហ្នឹងទាំងអស់វិញ ពួកអាប៉ុល ពតហ្នឹង លុះត្រាតែកែប្រែអាស្អីទាំងអស់ស្អីគេខ្លះបានអាចកែប្រែតែដូចអត់សូវឃើញ តែយើងមិនដឹងថាអាណាគេផងហ្នឹងមីងឥឡូវ!!

ខៈ ចាំ!!

កៈ មីងមានចាំមុខប៉ុល ពតអីវ៉ាន់រស់នៅដល់ឥឡូវស្គាល់អ្នកណាគេអីអត់?

ខៈ  មានតើ តែគ្រាន់តែថាយើងទៅធ្វើស្អី!!

កៈ  នៅភូមិស្រុកហ្នឹងជាមួយគ្នា?

ខៈ  ណោះនៅទួលក្រសាំងហ្នំ!!អាហ្នឹងអ្នកយកឪពុកញ៉ុមយកទៅសម្លាប់ចោលម៉ង!!

កៈ  នៅមីងស្គាល់មុខទៀត?

ខៈ ចាំ!!ប៉ុន្តែយើងដូចថារឿងកន្លងហួសហើយដូចថាយើងមិនតែដូចថាញ៉ុមនិយាយទៅស្រុកនេះមិនចេះចង ដូចថាចងពៀរ!!

កៈ គំនុំ!!
ខៈ ចងពៀរ ចងគំនុំ បើក្រៅពីស្រុកនេះវិញហាំងាប់បាត់ហើយ!!កៈ ចំ!!!ខៈ គេមិនទុកអោយនៅរស់ទេ។
កៈ ហើយចុះបងប្អូនមីងមានអ្នកណាគេខឹងអីខ្លះ?
ខៈ គេខឹង ខឹងអីដែរតើ តែខឹងទៅតាមដំនើរបើឥឡូវវាអញ្ចឹងទៅហើយ!!
កៈ តាមពិតហាអាពួកអស់ហ្នឹងមិនសមមកនៅក្នុងភូមិស្រុកហ្នឹងទេ សមតែរត់ទៅនៅអោយឆ្ងាយកុំអោយគេស្គាល់មុខហាបានត្រូវ។
ខៈ វាខ្ជិលស្រុកនេះវាស្លូតផង និយាយទៅស្រុកនេះស្លូតណាស់ ក្រៅពីស្រុកនេះនៅខាងបូព៌ាគ្រាន់តែថាហ្វូព្រឹបហាឡើងកាប់ដល់លើផ្ទះហ្ហ៎!!កៈ ហ៊ឺ!!ខៈ គេមិនទុកអោយរស់ទេ។
កៈ ហ្នឹងហើយហ្អែងខ្លាំងអីគេទៀត!!
ខៈ តែស្រុកនេះខ្ជិល!!
កៈ គំនុំហាំមីងសម្លាប់មនុស្សដែលយើងស្រលាញ់ណាស់មីង!!
ខៈ ចាំហ្នឹង!!មនុស្សអត់កំហុស!!
កៈ មីងពេលហ្នឹងបំរុងគេនឹងយកទៅដែរហ្នឹងមីងហេ?
ខៈ ញ៉ុមអត់ទេ ហ្នឹងពេលហ្នឹងគេយកឪពុកទៅសម្លាប់ចោលហើយអីហើយអស់ហ្នឹងបានគេបញ្ជូនស្រ្តីមេម៉ាយហ្នឹងទៅកោះខ្សាច់ជន្លាហ្នឹង!!
កៈ ហ្ហ៎!!
ខៈ ទៅហ្នឹងជូនទៅហ្នឹងដើរទៅទៀត មុនដំបូងគេអោយជិះអាត្រាក់ទ័រ អាត្រាក់ទ័រដាក់កន្ទុយរឺម៉ក់នោះ!!
កៈ ចាំចាំ!!
ខៈ ដល់ពេលហើយមិនដឹងអាម៉េចគេទេគេអោយចុះដើរទៅ ដើរទៅរហូតទៅទំរាំទៅដល់កោះខ្សាច់ជន្លាយប់ យប់អត់មានអីហូបទេ មានតែបបរព្រលិត!!
កៈ ហ៊ឺ!!
ខៈ គេបបរព្រលិតអោយយើងហូបហាំ!!
កៈ លាយអង្ករតិចៗទៅមីងហេ?
ខៈ ចាំ ហ្នឹងបបរព្រលិត បបរព្រលិចហ្នឹងគេទទួលយើងគេថាយើងប្រពន្ធពួកក្បត់ ម៉ែញ៉ុមហ្នឹងហាំគេថាប្រពន្ធពួកអាក្បត់ពួកអាសក្តិភូមិ យកទៅលុតដំហ្នឹងហាំ!!

កៈ ចុះបើគេពីដើមមកមានអី!!
ខៈ គេពិតគេយកយើងទៅលុតដំទេ យើងកើតមិនកើតគេយកយើងទៅសម្លាប់ចោលទាំងអស់ហ្នឹង!!
កៈ ចាំ!!
ខៈ តែគ្រាន់តែថាវាចៃដន្យវាថាវៀតណាមទៅចូលទៅទាន់ទេ កុំអីវាសម្លាប់ចោលទាំងអស់ហ្នឹង។
កៈ ហ្នឹងហើយ !! មីងញ៉ុមឮគេនិយាយថាគំរោងការគឺសម្លាប់មួយប្រទេសខ្មែរតែម្តង បណ្តាច់ពូជម៉ងមីងហេ!!
ខៈ ហ្នឹងហើយ!!
កៈ អាពេលធ្វើអីគេអាពេលធ្វើនំបញ្ចុកអោយហូបនៅថ្ងៃចុងក្រោយនោះ!!
ខៈ ចាំនៅថ្ងៃចុងក្រោយ!
កៈ តែជួនអីពេលហ្នឹងយួនចូលមកហ្នំ!! មីងពេលហ្នឹងមានបានហូបនំបញ្ចុកអីខ្លះអត់?
ខៈ អត់បានហូបទេ តែគ្រាន់តែថាកាលហ្នឹងគេគំរោងពិតមែន គំរោងហ្នឹងនៅបន្ទាយសេះគេប្រជុំ!!
កៈ ចាំ!!
ខៈ គេហៅថាសន្និបាតនោះ!!
កៈ ចាំ!!
ខៈ តែសន្និបាតគេហ្នឹងគេមិនទាន់បានធ្វើនំបញ្ចុកធ្វើនំអីគេគេទេ ដូចគេថាប្រុងដាក់មីនដាក់អីផ្ទុះសម្លាប់ម៉ងហាំ!!
កៈ ហ៊ីៗ!!
ខៈ តែថាអាអ្នកនេះនៅហ្នឹងវាមានម៉ែឪវានៅហ្នឹងដែរនោះវាមិនធ្វើទៅកើត!!
កៈ ហ៊ីៗ!!នៅចិត្តមួយហ្នឹង!!
ខៈ ចាំ!!
កៈ នៅតែក្រាលរំលឹកដែរមីងណោះ?
ខៈ ហ្នឹងហើយ វាធ្វើមិនកើតបានវាផ្អើលទឹលមកបាននេះហ្នឹង!!
កៈ យួនចូលមកបានរួចខ្លួនទៅមីងណោះ?
ខៈ ចាំ!!
កៈ យួនជួយ!! មីងមានដែលឃើញមានអ្នកណាគេយកមនុស្សទៅសម្លាប់ចោលផ្ទាល់ភ្នែកអីទេ?

ខ៖ ឃើញតើ!!
ក៖ ម៉េចទៅមីង?
ខ៖ ឃើញនៅកោះគរហ្នឹង ឃើញគេដាក់ចងសេកបណ្ដើរទៅម៉ោង៩ ម៉ោង១០យប់ហ្នឹងបណ្ដើរយកទៅហើយ!!
ក៖ ទាំងខ្សែ ទាំងខ្សែហ្នឹងទៅ!!
ខ៖ ចាំទាំងខ្សែ ទាំងខ្សែ!!
ក៖ ហើយដាក់លើទូកជិះទៅ?
ខ៖ ជិះទុកទៅទៅ!!
ក៖ ហើយចុះពួកអាអ្នកដែលគេចងហ្នឹងមិនព្រមតែកាំភ្លើង!!
ខ៖ ធ្វើស្អីកើត!!មានធ្វើស្អីកើត!!
ក៖ អត់ អត់រួមគ្នាយកកាំភ្លើងមកបាញ់ងាប់វិញទៅអត់!!
ខ៖ ធ្វើអត់កើត អត់ទេមួយៗធ្វើអត់កើតទេ!!
ក៖ ញ៉ុមឆ្ងល់មួយៗពេលហ្នឹងនាំគ្នារួបរួមគ្នាពេលហ្នឹងអត់កើតម៉ង?
ខ៖ អត់ទេអត់កើតទេ។
ក៖ វាណែនពេញប្រទេសម៉ងមីងហេ?
ខ៖
ណែនពេញប្រទេសដូចបើគេចងបណ្ដើរយើងទៅជាប់គេមានកាំភ្លើងយើងដៃទទេហ្នឹងទៅធ្វើស្អីកើតបើគេចងសេកយើងជាប់ហើយហ្នឹង
ចុះទូកយកទៅជូនកាលឡើងទៅដល់ឡើងមិនទាន់ដាក់ផ្ទូងទំលាក់ទឹកទៅ!!
ក៖ ហ៊ឺ!!
ខ៖ បាញ់ផ្ទូងទំលាក់ទឹកទៅ!!ស្រែកអាយេអាយូ ឮសំលេងស្រែកតើ!!
ក៖ មីងពេលហ្នឹងនៅកន្លែងណាវិញបានឮសំលេង?
ខ៖ ញ៉ុមនៅអើរនៅមាត់ទន្លេកន្លែងហ្នឹង!!
ក៖ អូយហើយឮម៉ងមីងហេ?
ខ៖ នេះនៅទន្លេកន្លែងនេះ កាលហ្នឹងរោងបាយវានៅនេះជាប់ផ្លូវហ្នឹងម៉ង!!ក៖ ហ៊ឺ!!ខ៖ រោងបាយវាពីអាពត។
ក៖ ឮស្រែកពេញហ្នឹងមីងហេ?
ខ៖ ឮស្រែកពេញហ្នឹងអាយែអាយ៉ូ យ៉ូយៗម៉ែអើយជួយកូនផង ឡើងក្រលួចទៅ!!

កៈ អើយមីងអើយមីង ហើយមីងដល់ពេលបែកប៉ុល ពតមកមានទៅមើលឆ្លងទៅត្រើយម្ខាងទៅមើលឆ្អឹងអីហ្នឹងទេ?
ខៈ អត់ទេ អត់បានឆ្លងទេ កាលភ្លាមហ្នឹងយើងអាលែងទៅឆ្លងទៅអីណាតែដល់យូរហើយបានគេទៅធ្វើបុណ្យទៅធ្វើអីពីណោះអញ្ចឹងទៅ
ទៅមើលទៅឆ្អឹងវានៅស្រស់ៗដែរហ្នឹងវានៅមានក្លិននៅមានអីដែរអ៊ីចឹងហាំ!!នៅក្នុងរណ្ដៅហ្នឹង!!
កៈ ចាំ!!
ខៈ រណ្ដៅធំៗហោមីងពេលហ្នឹង?
ខៈ រណ្ដៅធំៗតើ!!
កៈ ចាំ!!
ខៈ វាមានឆ្អឹងខ្លះវារលួយខ្លះមិនទាន់រលួយ។
កៈ តែខោអាវឃើញអីវ៉ាន់ពេញហ្នឹងទៅមីងហោ?
ខៈ ចាំ!!
កៈ
ញ៉ុមឮញ៉ុមសំភាសន៍ពូផល្លីគាត់និយាយថាអ្នកណាគេទេដល់ពេលបែកអ៊ីចឹងហើយទៅរើអាឆ្អឹងខ្មោចហ្នឹងដោយសារអញ្ចេកខោអាវពូកចាស់ៗដេរអញ្ចេះហ្នំមីង!!
ខៈ ហ្នឹងហើយ!!
កៈ មានមាសមានអីអញ្ចឹងទៅមីងហោ?
ខៈ ហ្នឹងហើយ។
កៈ អញ្ចឹងមីងធ្លាប់ឮដែរតើមីងហោ?
ខៈ ធ្លាប់ឮតើ គេជីកមាសជីកអីបានតើនៅហ្នឹង។
កៈ ចាំ!!
ខៈ តែគេជីកបានគេនិយាយទៅថាមេវានៅហ្នឹងម៉ងហាំដូចថាវាប្រមូលអ្នកទោសអញ្ចឹងទៅដាក់ក្នុងកេសក្នុងអីគេបង្កប់ទៅណាស់
បើវាដឹងកន្លែងវាមិនមកគាស់យក!!
កៈ ហ៊ឺៗ!!
ខៈ គាស់យកទៅទៅ!!

ក៖ មីងពេលបែកពីជំនាន់ប៉ុល ពតមកមានអារម្មណ៍ម៉េចដែរ ដល់ពេលយួនចូលមកគិតថារួចខ្លួនហើយមានអារម្មណ៍គិតថាប្រឈមមុខនឹងការគេយកទៅសម្លាប់ចោលទៀតហ្អ??

ខ៖ អើយវៀតណាមចូលមកយើងនៅក្មេងដែរ ដូចថាអញ្ចេកមិននឹកឃើញថារឿងអីផ្សេងទេណាស់ នឹកឃើញថាយើងបានស៊ីបាយបាយឯកជនខ្លួនឯងវាឆ្អែតពេញពោះ ហើយក៏នឹកឃើញថាវាយ៉ាងម៉េចយ៉ាងម៉ាអីដែរ គ្រាន់តែថាពេលដែលនឹកឃើញម្តងៗ ឃើញអញ្ចេះពេលដែលទៅរៀន ពេលដែលធ្វើការហាត់អស់កំលាំងនឹកឃើញថាបើសិនជាឪអញនៅប្រហែលជាអត់ហាត់អត់នឿយអញ្ចឹងទេ ហើយក៏អត់មានបានអីដែរបានរៀនសូត្រនឹងគេហើយ នឹកឃើញអញ្ចឹងហាំ!! ហើយនឹកឃើញថាមានអារម្មណ៍ក្តុកក្តួលអញ្ចេះមើលទៅគេនៅជុំគ្នាយើងបែកឪពុកម្តាយមីងមួយក៏ស្លាប់ទៅទៀតអាពតសម្លាប់ ឪពុកសម្លាប់ចោលទាំងអស់អ៊ីចឹងហាំគ្រាន់តែនឹកឃើញតែប៉ុណ្ណឹងទេ!!

ហើយដល់ពេលហាត់អញ្ចឹងទៅចេះតែនឹកឃើញវែងឆ្ងាយទៅមនុស្សយើងម្នាក់ៗតែងតែនឹកឃើញហើយដូចថាយើងនៅជុំគ្នាវាមានភាពកក់ក្តៅ!!

ក៖ ដល់ពេលបែកឪពុកអ៊ីចឹងទៅ!!

ខ៖ ចាំ!!

ក៖ រកស៊ីពិបាក។

ខ៖ យើងបែក បើបែកត្រឹមតែថាធម្មតាមិនអីទេណាស់បែកបង្អែកមួយដែលយើងសំរាប់ផ្អែកហាំ!!

ក៖ ធំម៉ង!!

ខ៖ មាំហាំ ចាំ អ៊ីចឹងទៅវាពិបាក ចុះម្តាយស្រីហើយគាត់ទៅធ្វើស្អីណាបានធំដុំដូចមនុស្សប្រុស!!

ក៖ ចាំ!!

ខ៖ ហើយណាមួយយាយជរាទៀត ទៅណាចោលកើតទៅណាធ្វើអីកើត!!

ក៖ ហ៊ឺៗ!!ចាំអញ្ចឹងមីងបន្ទាប់ពីបែកប៉ុល ពតមករកស៊ីលក់ស្ពៃជ្រក់ រកស៊ីលក់អន្សមខ្ទុរហាំ!!

ខ៖ លក់អន្សមដំឡូង!

ក៖ លក់អន្សមដំឡូងអីវ៉ាន់មកជាមួយម៉ែរហូតមក?

ខ៖ ចាំ!!

ក៖ ហើយបានបានមានប្តីមានកូនអីអញ្ចឹងទៅមីងណោះ?

ខ៖ ចាំ!!
ក៖ ចុះដល់ពេលមីងមានប្ដីមានកូនមកមីងរកស៊ីអីគេដែរមីង?
ខ៖ ញ៉ុមមានប្ដីមានអីមកកាលហ្នឹងប្ដីគេធ្វើទាហានកាលហ្នឹង។
ក៖ ចាំ!!
ខ៖ ចាំប្ដីធ្វើទាហាន!!
ក៖ ហ្អូ!!!ទាហានហ្នឹងគឺល្បីណាស់អារឿងមានស្រីហ្នឹង!!
ខ៖ ហ្នឹងហើយ!!
ក៖ គឺអត់ចោលតែម្ដង!
ខ៖ ធ្វើទាហាន។
ក៖ ចាំហើយចុះដល់ពេលមកក្រោយទៀត ពូមកក្រោយធ្វើអីគេដែរពូស្វាមីក្រោយមីងហាំ?
ខ៖ ពូស្វាមីក្រោយនេះហោ?
ក៖ ចាំ!!
ខ៖ គាត់ស៊ីឈ្នួលរត់គុអីអោយគេជូនកាលបាញ់ទឹកបន្លែស៊ីឈ្នួលបាញ់ទឹកបន្លែបាញ់អីអោយគេអីចឹងទៅ។
ក៖ ចាំ!!
ខ៖ ទឹមតែមកចូលបានមកធ្វើការហ្នឹងរោងចក្រហ្នឹងអីបន្តិចបន្តួចអីចឹងទៅ ធ្វើឈប់ធ្វើឈប់អញ្ចឹងទៅ!!
ក៖ អញ្ចឹងមីងអត់មានដីដាំចំការអីដូចគេទេហោ?
ខ៖ អត់ទេ អត់មានអីសោះម៉ង!!
ក៖ មកចាប់ មីងពេលមកប៉ុល ពតហ្នឹងហើយ ចាប់ដីអត់បានធំនឹងគេឬក៏យ៉ាងម៉េច?
ខ៖ អត់បានទេព្រោះអីអញ្ចេក ព្រោះអីអង្កាល់ហ្នឹងម៉ែ យើងនៅក្មេងៗហាំ!!
ក៖ ចាំ!!
ខ៖ មិនដឹងគេចែកអីត្រង់ណាចែកអីយើងអត់ដឹងទេតែគ្រាន់តែដឹងថាម៉ែមានតែដីនៅត្រឹមតែមួយផ្ទះនៅទេ ដីស្រូវ ស្រូវវស្សាគាត់លក់អស់អញ្ចឹងទៅមើលជំងឺគាត់អីអញ្ចឹងទៅណាស់!!
ក៖ ចាំ!!
ខ៖ ទំរាំគាត់ស្លាប់ មើលដីមួយក្បាលហ្នឹងក៏គាត់លក់ដែរ!!
ក៖ អញ្ចឹងដីមីងតាំងពីមុខផ្លូវរហូតបណ្ដាក់ៗមកអញ្ចឹងរហូតម៉ងហោ?

ខ៖ ចាំ តែអានេះលក់អោយគេអញ្ជឹងទៅក្រោយនេះលក់អោយគេអញ្ជឹងទៅ លក់មើលគាត់ហាំតែគាត់នៅតែមិនរស់ទៀតមិនដឹងធ្វើម៉េច។

ក៖ គាត់ឈឺអីគេវិញយាយ?

ខ៖ យាយឈឺបេះដូងផង គាត់ជំងឺបេះដូងផង គាត់ទឹកនោមប្រៃផង គាត់ក្រលៀនផង!!

ក៖ ហ្នឹងហើយអ្នកមីងប្រាប់!!ចាំ!!

ខ៖ គាត់ខ្សោយក្រលៀន យកទៅពេទ្យសម្តេច ទៅដល់ពេទ្យគេថាហួសពេលមើលហើយហ្នឹង!!

ក៖ ក៏ទុកតាមដំនើររហូតដល់ថ្ងៃស្លាប់អញ្ជឹងទៅមីងណោះ?

ខ៖ ហ្នឹងហើយចាំ!!!

ក៖ មីងសំរាប់ជីវិតរបស់អ្នកមីងហាំសង្ឃឹមទៅពេលថ្ងៃខាងក្រោយសង្ឃឹមអីគេដែរ ដូចជាគិតថានឹងអាចពឹងពាក់បានឬក៏ម៉េចសង្ឃឹមអញ្ជឹងហាំម៉េចដែរ?

ខ៖ ញ៉ុមហេបើសិនជាសង្ឃឹមគឺអត់មានសេចក្តីសង្ឃឹមទេ !!

ក៖ ចុះកូន សង្ឃឹមអីពីកូនដែរ?

ខ៖ កូនអត់សង្ឃឹម។

ក៖ ហើយម៉េចបានអញ្ជឹងវិញ?

ខ៖ ព្រោះអីញ៉ុមនិយាយត្រង់នេះ ញ៉ុមនិយាយហែកកេរ្តិ៍ខ្លួនឯងឬមួយក៏ចង់អោយអស់លោកណាជួយថាអានិតទេណាស់ព្រោះ កូនពឹងអត់បាន!!

ក៖ គេរៀងខ្លួនគេហី?

ខ៖ អ៊ីចឹងបានញ៉ុមអត់មានសង្ឃឹមអ្នកណាគេមួយក្រៅពីប្តីទេ តែបើអត់ពីប្តីទៅគឺចប់ហើយ។

ក៖ ហ៊ឺៗ!!

ខ៖ អាហ្នឹងញ៉ុមក៏ធ្លាប់និយាយជាមួយប្តីដែរ !!

ក៖ ចាំ!!

ខ៖ ហើយប្តីញ៉ុមគាត់ក៏ដឹងដែរ ញ៉ុមថាសព្វថ្ងៃញ៉ុមមានតែឯងមួយទេ បើសិនជាអត់ពីឯងទៅញ៉ុមចប់ហើយ។

ក៖ មិនដឹងពឹងអ្នកណាគេ!!

ខ៖ ញ៉ុមអត់អាចរស់នៅបានទេ !! ចាំញ៉ុមអត់ដឹងពឹងអ្នកណាគេទេ!! ខ្ញុំសព្វថ្ងៃប្រៀបដូចជាក្បូននៅកណ្តាលទន្លេអ៊ីចឹង!!

ក៖ ចាំ!! តែមានពូមួយទប់ទល់មីង!!

ខ៖ ចាំ!!ញុំមដូចសព្វថ្ងៃនេះ ងាកទៅឆ្វេងខុយ ងាកទៅស្ដាំខុយម៉ងរាល់ថ្ងៃនេះ!!

ក៖ ហ៊ីអញ្ចឹងដូចរាល់ថ្ងៃអ្នកមីងប្រាប់ញុំមថារកលុយមកដើម្បីដោះបំណុលគេមីងហោ?

ខ៖ ចាំ!!

ក៖ ហើយមូលហេតុអីទៅជំពាក់គេអញ្ចឹងមីង?

ខ៖ ចុះយើងកាលហ្នឹងកូននៅទូចៗ។

ក៖ ការកូនការអី?

ខ៖ កាលការកូនអត់មានខ្វល់រឿងអីជំពាក់គេទេ!!

ក៖ ចាំ!!

ខ៖ កូននៅទូចៗញុំមតែម្នាក់ឯង។

ក៖ អូយអីចឹងយូរណាស់ហើយមីងហោ?

ខ៖ ចាំ!!!បំណុលហ្នឹងគឺមិនមែនទឹមតែមកឥឡូវទេ បំណុលហ្នឹងតមកយូរហើយ តែតមកការជាដើម ដើមជាការហាំអីចឹងហាំបានជំពាក់គេអត់ចេះចប់!!

ក៖ ឥឡូវប៉ុន្មានពាន់?

ខ៖ ញុំមលក់ផ្ទះហ្នឹងអស់ពីរហើយ ញុំមលក់ដោះសងគេបានតែដើមទេ កន្ទុយគេនៅទាំងអស់ អើរបានតែកន្ទុយក្បាលនៅទាំងអស់ អញ្ចឹងញុំមលក់ផ្ទះអស់ពីរហើយ ញុំមបានប៉ាវាមក បានប៉ាវាមកញុំមចាប់ឈឺ ឈឺហាំឈឺនៅតែញុំមមួយទេ គាត់ក៏ឈឺ កូនក៏ឈឺ ឈឺទាំងបី អញ្ចឹងញុំមនៅតែម្នាក់ឯងជ្រោង ជ្រោងអត់រួចទេ ជំពាក់ថ្លៃពេទ្យចងការឯកជនអោយពេទ្យ ដល់អញ្ចឹងទៅលើកមួយដាក់មួយ

ដល់យើងនិយាយប្រៀបធៀបទៅយើងលើកមួយដាក់មួយដល់អ្នកនេះយកពីអ្នកនោះមក!!

ក៖ ហ៊ីៗ!!

ខ៖ ដល់ពេលដល់ខែនេះយកពីអ្នកផ្សេងយកមកដាក់អ្នកនេះទៀតដើម្បីយកមកដោះគេហាំ!!

ក៖ ចាំ!!

ខ៖ ការប្រាក់គេហាំ ដល់ហើយឡើងគរ គរ ចូលរហូតទល់តែសព្វថ្ងៃហ្នឹងមកបំណុល!!

ក៖ ហ៊ីៗ!!

ខ៖ ដោយសារយើងវាដៃខ្លីជើងខ្លីអត់មានមុខរបរ បើនិយាយទៅយើងអត់មានមុខរបរ ។

ក៖ យ៉ាប់ណាស់អ្នកមីង!!

ខ៖ មិនរកអីធ្វើអី!!ចាំ!!ម្លោះហើយបានវាជាប់បំណុលរហូតមកដល់សព្វថ្ងៃហ្នឹង!!

ក៖ ឥឡូវប៉ុន្មានទៀតមីងបានរួចគេ?

ខ៖ ញុំមនៅ១០០០ជាងទៀត!!

កៈ ហ្ហ៎អឺចឹងប៉ុន្តែគេអត់មានយកការយកអីណាមីងហី?

ខៈ ១០០០ជាងទៀតហ្នឹងគេនៅយកការតើ តែគ្រាន់តែថាយកការតិចតួច!!

កៈ ហើរបានហើយការយូរណាស់ហើយល្មមបានហើយ!!

ខៈ គេអត់ព្រមទេ។

កៈ ដូចពេលខ្លះដល់ពេលអាក្រក់ពេក!!

ខៈ ញ៉ុមជំពាក់គេបើនិយាយរួមទៅជំពាក់គេតែ៧០០ទេ។

កៈ ការជាដើម ដើមជាការអញ្ចឹងទៅកើនរហូត?

ខៈ ចង់ម៉ឺន។

កៈ ចំ!!

ខៈ ចង់ម៉ឺនហាំ!!៨០០០ ៩០០០ហាំ (ដុល្លារ)!!

កៈ តែ៧០០សោះ?

ខៈ ចាំ៧០០ ញ៉ុមយកមកវះត្រចៀកអោយប្តី។

កៈ ហ៊ឺ!!

ខៈ មុនដំបូងញ៉ុមយកលុយគេ៥០០ ៥០០ដឹងគេដកម៉េចទេ?៥០០គេដក៥០!!

កៈ ហ៊ីដកហើយស្រាប់!!

ខៈ បានតែ៤៥០ សល់តែ៤៥០ទេណាស់ ដល់ថ្ងៃក្រោយមកទៀតប្តីនៅដេកពេទ្យទៀត ហើយអត់មានអីហូប ហើយណាមួយញ៉ុមនៅមើលប្តីទៀតញ៉ុមទៅយករបស់គេ២០០ទៀត ២០០គេដក២០រៀលទៀតបានតែ១៨០ទេ!!

កៈ អើយមីងអើយមីង!!

ខៈ ណាស់ !!ដល់ពេលហើយមុនដឹងគេយកប៉ុន្មានអត់?មុនយើងបង់ការអោយគេរហូតខានបង់អោយគេ២ឆ្នាំអាហ្នឹងយើងដាបមែនទែនហើយណាស់ ដល់ឃើញថាខ្លួនដាបមែនទែនហើយឡើង៨០០០ជាង។

កៈ ចំ!!

ខៈ លុយ៧០០ហា!!

កៈ ហ៊ឺ!!

ខៈ ហ្នឹងហើយញ៉ុមប្រាប់!!

កៈ តែឥឡូវសេងសល់តែ១០០០ជាងទេ?

ខៈ សល់ជាង១០០០ទេ។

កៈ ហើយពេលហ្នឹងលក់ដីលក់ផ្ទះដាច់!

ខៈ បើសិនជាមានដីមានផ្ទះលក់ហាំញ៉ុមលក់សងគេ។

កៈ ចុះឥឡូវផ្ទះនេះម៉េច?

ខៈ ញ៉ុមអត់សុខចិត្តលក់ដីផ្ទះទេ ដើម្បីទុកសរសេរអោយកុនដោតនៅ!!

កៈ ចាំ!!

ខៈ

សុខចិត្តលក់ផ្ទះនៅក្រោមដើមឈើតើ!!ញ៉ុមនៅក្រោមដើមឈើញ៉ុមកូនខ្ចីញ៉ុមនៅក្រោមដើមឈើ ប្តីដាក់សារ៉ូមនៅនឹងដៃញ៉ុមនៅក្រោមដើមខ្នុរហ្នឹង ប្តីនៅសារ៉ូមនៅនឹងដៃអញ្ចឹងហិញ៉ុមដេកនៅក្រោមដើមខ្នុរភ្លៀងមកញ៉ុមរត់ជ្រកផ្ទះគេញ៉ុមពោះប៉ុនកញ្ជើ ញ៉ុមពោះធំប៉ុនកញ្ជើ!!

កៈ អាពោះធំអាអូនក្រោយនេះហ្នឹង?

ខៈ ចាំ!!កូនញ៉ុមអាក្រោយហ្នឹង ប្តីញ៉ុមដាក់សារ៉ូម ញ៉ុមពោះធំប៉ុនកញ្ជើរញ៉ុមដេកនៅក្រោមដើមខ្នុរទេ កន្លែងហ្នឹងហិ!!

កៈ ឥឡូវកាប់ចោលបាត់ហើយហោ?

ខៈ កាប់ចោលបាត់ហើយ។ អើយញ៉ុមដាក់ដើមមៃកខ្នុរទើរមុង ទើរកន្ទេល កូនញ៉ុមមមីមួយបងញ៉ុមទៅទូលលតលក់ហាំញ៉ុមពោះប៉ុនកញ្ជើរញ៉ុមពោះធំ៨ខែ ញ៉ុមទៅលក់លតហើយគេលក់កូនឈើអោយទូចៗហាំ!!!ញ៉ុមលក់លតហើយញ៉ុមអូសរទេះដាក់ដើមឈើហ្នឹងភ្លៀង ភ្លៀងកូនវាជួយអូសមក វាអូសមកយកអាឈើ យកអាកន្ទេលមុងយកទៅធ្វើរផ្ទះមីងវា ដឹងប្តីគេថាម៉េចទេ?ញ៉ុមឆ្អែតទល់សព្វថ្ងៃ ញ៉ុមនឹកពេលណាញ៉ុមនឹកទឹកភ្នែក។

កៈ ម៉េចវិញមីង?

ខៈ ញ៉ុមនឹកឃើញពេលណាញ៉ុមនឹកទឹកភ្នែក គេថាស្វានៅតែដើមឈើកុំមកយកដាក់ផ្ទះអញ។

កៈ ហ៊ីសុទ្ធតែអ៊ីចឹងទៀត?

ខៈ ហ្នឹងហើយ។

កៈ ប្អូនថ្លៃ?

ខៈ ប្អូនថ្លៃ ញ៉ុមនឹកឃើញញ៉ុមឆ្អែតទល់សព្វថ្ងៃ ញ៉ុមនឹកឃើញឆ្អែតញ៉ុមនឹកឃើញទឹកភ្នែករហូត!!ពីនាក់ប្តីប្រពន្ធ!!

កៈ ហើយគ្រាន់តែប៉ុណ្ណឹងសោះ!!

ខ៖ ហើយប្តីដាក់សារ៉ូមហា៎ ប្តីអត់ហូបអីកើតទាំងអស់ ហើយញ៉ុមដាក់ផ្តេកលើស្មាញ៉ុមបញ្ចុកបបរទេណាស់ប្តីញ៉ុមហា៎ ចាំសួរមើលហ្នូ!!!
ក៖ ហ៊ី!!!
ខ៖ ដាក់ក្បួត ដាក់ក្បួតទាំងអស់ គ្រុនពោះវៀន!!វាជ្រុល!!
ក៖ ប្តីអ្នកមីងក្រោយហ្នឹងហោ?
ខ៖ ហ្នឹងប្តីញ៉ុមក្រោយហ្នឹង!!
ក៖ ចា៎!!
ខ៖ ញ៉ុមផ្តែកដាក់លើស្មាញ៉ុមបញ្ចុកបបរ!!
ក៖ ចា៎!!
ខ៖ ញ៉ុមពោះប៉ុនកញ្ជើរផ្តែកបញ្ចុកបបរប្តីហ្នឹង អោបប្តីទៅពេទ្យមណ្ឌលហ្នឹង ហើយពេលពេទ្យមណ្ឌលហ្នឹងពេលទៅដល់គេយកលុយដែរ តែដល់ពេលមកក្រោយនេះដឹងម៉េចអត់?បាននឹកឃើញប្រវត្តិហ្នឹងញ៉ុមវាឆ្អែតដែរ!!ខ្ញុំចាក់ថ្នាំអោយប្តីអោយលុយគេប៉ុន្មានទេ ដូចជា៨០០០ខ្វះគេប៉ុន្មានទេ!!!គេបោះលុយនៅនឹងដីចោលហា៎ គេថាលុយវាអត់គ្រប់គេអត់យកទេ។
ក៖ ចំ!!
ខ៖ បោះព្រុសចោលនៅហ្នឹងដីហា៎!!
ក៖ អើយ!!
ខ៖ គេបោះព្រុសចោលនៅហ្នឹងដីគេអត់យកទេញ៉ុមប្រាប់ ហើយប្តីញ៉ុមនៅដេកនៅដាក់សារ៉ូមហា៎!!
ក៖ តែពេលខ្លះក៏យល់ដែរថាគ្នាពិបាក វេទនា។
ខ៖ អត់!! ហើយមកដល់ឃើញស្រាប់ហើយហើយឃើញនៅហ្នឹងភ្នែកទៀតថាញ៉ុមហ្នឹងវាអត់មានផ្ទះអត់មានសម្បែងនៅទេ នៅក្រោមដើមឈើនៅខ្ទមអញ្ចឹងហា៎!!លុយអត់មានទុកទិញអង្ករហូបទេ សុខចិត្តទុកអោយពេទ្យទៅ កាលហ្នឹងអោយគេ៨០០០ កាលហ្នឹងគេយក៣រៀលហ្នឹងហើយ!!គេយក១២០០០ណាហើយដល់ហើយញ៉ុមមានតែ៨០០០ ខ្វះគេ៤០០០ បោះលុយចោលនៅនឹងដីព្រុស!!
ក៖ ហ៊ី!!
ខ៖ ប្តីញ៉ុមអោនរើសលុយទាំងទឹកភ្នែក ពូ ពូឯងយកលុយប៉ុណ្ណឹងសិនទៅ ទ្រាំទៅ!!
ក៖ ពេលខ្លះមនុស្សដល់ពេលធ្វើកាដេថីអញ្ចឹងក៏មិនកើតដែរមីងអើយ!!!

ខ៖  បានលុយបោះចោល បោះលុយចោលនៅមុខហ្នឹង!!
ក៖
អញ្ចឹងញុំមសង្ឃឹមថាដូចជាអ្វីដែលញុំមបានប្រាប់អញ្ចឹងនឹងថានឹងអាចជួយមីងបានអញ្ចឹងហាំ!
!
ខ៖ ចាំ!!
ក៖
ដោយសារខាងអង្គការគេហ្នឹងអីវ៉ាន់ជួយអ្នកណាគេស្រ្តីណាដែលអត់មានការងារធ្វើអីវ៉ាន់អញ្ចឹងដើម្បីមានមុខរបរធ្វើខ្លួនឯង ដូចរបៀបថាបង្រៀនអោយចេះស្ទូចត្រីអីចឹងអ្នកមីងហាំ!!
ខ៖ ចាំ!!
ក៖ បើសិនជាអោយត្រីហ្នឹងទៅវានឹងអស់ហើយត្រីហ្នឹងហ្នំ!!
ខ៖ ចាំ!!
ក៖ ថ្ងៃណាមួយតែដល់ពេលអោយសន្ទូចអោយផ្លែអីអញ្ចឹងទៅ!
ខ៖  ចាំអោយចេះស្ទូចខ្លួនឯង!!
ក៖
គឺថាមករហូត!!អញ្ចឹងបានថាទោះម៉េចៗមួយថ្ងៃយើងរកបាន១០ដុល្លារអញ្ចឹងទៅមួយខែក៏យើញជិត៣០០ដុល្លារដែរអ្នកមីងហាំ!!
ខ៖ ចាំ!!ហ្នឹងហើយ!!
ក៖ អញ្ចឹងប៉ុន្មានខែទៅអាចនឹងដោះសងគេរួចមួយហ្នឹងហើយ!!
ខ៖  ហ្នឹងហើយ។
ក៖ ហ្នឹងហើយមានអារម្មណ៍ថាមិនមែនព្រះយកមកអោយមីងដោយផ្ទាល់ទេ ប៉ុន្តែដូចរបៀបថាប្រាប់តាមតតាមអ្នកណាគេផ្សេងអញ្ចឹងទៅណាស់!!
ខ៖ ចាំ!!!
ក៖ ហើយញុំមដឹងអីចឹងៗហើយញុំមអត់លាក់ទេ ញុំមចង់ជួយអ្នកផ្សេងទៀតដើម្បីអោយគាត់មានមុខរបររកស៊ីដែរ!!!
ខ៖ ចាំ!!
ក៖ កុំអោយពិបាកអីចឹងអ្នកមីងហាំ!!
ខ៖ ចាំ!!
ក៖
អញ្ចឹងមីងមួយនេះគឺជាសំនួរមួយចង់ក្រោយមានអីគេផ្តែផ្តាំទៅកាន់កូនចៅជំនាន់ក្រោយថា

អោយពួកគាត់ដើរលើផ្លូវម៉េចដែរក៏ដូចជាអោយគាត់ជៀសផុតពីផ្លូវអីគេដែរអញ្ចឹងអ្នកមីងហាំ??

ខ៖ ញ៉ុមអត់មានពាក្យពេចន៍អីច្រើនទេ គ្រាន់តែញ៉ុមចង់ផ្តែផ្តាំកូនចៅជំនាន់ក្រោយអោយធ្វើអ្វីតាមភាពត្រឹមត្រូវខ្លួនឯងកុំធ្វើភ្លើតភ្លើន ហើយធ្វើអ្វីអោយមានភាពសមរម្យ បើធ្វើមិនត្រូវកុំធ្វើបើធ្វើមិនត្រូវកុំបំពាន ធ្វើអ្វីក៏ដោយអោយតែមានភាពសុចរិតទៅ!!

ក៖ ចាំ អោយគាត់គេចផុតពីផ្លូវអីគេដែរអ្នកមីង?

ខ៖ ចាំអោយគេចផុតពីគ្រឿងញៀន គេចផុតពីអ្វីៗដែលថាដឹកនាំអោយមិនល្អហ្នឹងហាំ !!

ក៖ ហ៊ីៗ!!

ខ៖ កុំអោយទៅមានភ្លើតភ្លើនអីមិនល្អអោយសោះ។

ក៖ ចាំហ្នឹងហើយ អ៊ីចឹងអ្នកមីងមានអីចង់ផ្តែផ្តាំ មានតែប៉ុណ្ណឹងឬក៏មានអីគេទៀត?

ខ៖ អត់ទេ!

ក៖ ចាំអញ្ចឹងអរគុណច្រើនអ្នកមីងសំរាប់ការសំភាសន៍នៅក្នុងថ្ងៃនេះញ៉ុមដឹងថាកូនអ្នកមីងគាត់នឹងបានស្តាប់ឮក៏ដូចជាអ្នកខ្លះចង់បានរៀននឹងសិក្សាពីប្រវត្តិប្រជាជនខ្មែរក៏ដូចជាជីវប្រវត្តិរបស់អ្នកមីងក៏ដូចជាអ្នកផ្សេងអញ្ចឹងទៀតណាស់អ្នកមីង!!

ខ៖ ចាំ!!

ក៖ ចាំអរគុណច្រើន។